# សៀវភៅសំរាប់អ្នកហ្វឹកហ្វឺនការអប់រំ
# ពលរដ្ឋ និង អ្នកបោះឆ្នោត

★ <u>សេចក្តីថ្លែងអំណរគុណ</u>

សៀវភៅសំរាប់អ្នកហ្វឹកហ្វឺនការអប់រំពលរដ្ឋ និង អប់រំអ្នកបោះឆ្នោត ព្រមជាមួយឯកសារបន្ថែមសំរាប់អមឯកសាររបស់អ្នកហ្វឹកហ្វឺនអប់រំគេនេះ បានត្រូវចងក្រងឡើងដោយមានជំនួយជួយជ្រោមជ្រែងពីបុគ្គលជាច្រើនរូប ដែលមានការងារពាក់ពន្ធ័ក្នុងវិស័យ ការអប់រំពលរដ្ឋ និង ការត្រួតពិនិត្យមើលការបោះឆ្នោតនៅរាជធានីភ្នំពេញនៃកម្ពុជា ។ វិជ្ជាស្ថានប្រជាធិបតេយ្យជាតិ សំរាប់កិច្ចការអន្តរជាតិ (NDI) សូមសំដែងសេចក្តីរីករាយដល់ការជួយជ្រោមជ្រែង ពីសម្ព័ន្ធគាំទ្រការបោះឆ្នោតដោយសេរី និង យុត្តិធម៌ (COFFEL) និងគណៈកម្មការដើម្បីយុត្តិធម៌ក្នុងការបោះឆ្នោតនៅកម្ពុជា (COMFREL) ដែលបានផ្តល់ដល់យើងខ្ញុំ នូវទស្សនៈដ៏មានតំលៃ ព្រមទាំងផលប្រយោជន៍នៃបទពិសោធន៍របស់គេ ។

អង្គការ NDI ក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅផងដែរ ដល់អង្គការទាយជ្ជទានជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ ដែលបានផ្តល់ថវិកាជួយដល់កម្មវិធីនេះ ។

*មនុស្សសំខាន់ដែលបានរួមចំណែកមាន ៖*

Elise P. Schoux
Peter M. Manikas
Sohie D. Richardson

ឯកសារនេះ គឺជាផ្នែកមួយនៃការជួយជ្រោមជ្រែងរបស់ NDI លើការអប់រំពលរដ្ឋ និង ការត្រួតពិនិត្យមើលការបោះឆ្នោត ដោយមានអង្គការពលរដ្ឋនានា ដែលមិនមានគំនិតប្រកាន់បក្សពួក នៅក្នុងលទ្ធិប្រជាធិបតេយ្យអន្តរកាល ។

★ <u>មាតិការអត្ថបទ</u>


I. <u>ការណែនាំអំពីសៀវភៅហ្វឹកហ្វឺន</u>

ការរៀបចំរបស់អ្នកហ្វឹកហ្វឺនអប់រំគេ ..........................................

ក្រមសីលធម៌/ច្បាប់ទូន្មានខ្លួនសំរាប់អ្នកអប់រំគេ ..........................................

លទ្ធផលរកឃើញរបស់ក្រុមមុខសញ្ញាស្តង់មតិ ..........................................

II. <u>ផ្នែកទីមួយ</u> : សេចក្តីណែនាំអំពីវគ្គបណ្តុះបណ្តាល

សេចក្តីផ្តើម ..........................................

របៀបវារៈ ..........................................

III. <u>ផ្នែកទីពីរ</u> : តើលទ្ធិប្រជាធិបតេយ្យជាអ្វី ?

លំហាត់ : ការរៀបរាប់អំពីលទ្ធិប្រជាធិបតេយ្យ ..........................................

ការផ្តល់ពត៌មានអំពី : តើលទ្ធិប្រជាធិបតេយ្យជាអ្វី ? ..........................................

ការផ្តល់ពត៌មានអំពី : លក្ខណៈនៃលទ្ធិប្រជាធិបតេយ្យ ..........................................

លំហាត់ : សារៈប្រយោជន៍នៃលទ្ធិប្រជាធិបតេយ្យ ..........................................

ការផ្តល់ពត៌មានអំពី : លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ..........................................

IV. <u>ផ្នែកទីបី</u> : ការអប់រំអ្នកបោះឆ្នោត

ការផ្តល់ពត៌មានអំពី : តើការបោះឆ្នោតជាអ្វី ? ..........................................

ការផ្តល់ពត៌មានអំពី : តើហេតុអ្វីចាំបាច់បោះឆ្នោត ? ..........................................

លំហាត់ : គោលការណ៍ជាមូលដ្ឋាននៃការបោះឆ្នោត ..........................................

ការផ្តល់ពត៌មានអំពី : តើអ្នកបោះឆ្នោតមានសិទ្ធិអ្វីខ្លះ ? ..........................................

លំហាត់ : តើយើងអាចធ្វើយ៉ាងណាដើម្បីអោយមានការបោះឆ្នោតសេរី និង មានយុត្តិធម៌ ...

ការវាយតំលៃ : ..........................................

V. <u>ឯកសារបន្ថែមនៅលើសៀវភៅរបស់អ្នកអប់រំគេ</u>

វគ្គទីមួយ : គោលបំណងរបស់ឯកសារបន្ថែម ..........................................

វគ្គទីពីរ : ប្រវត្តិនៃការបោះឆ្នោតនៅកម្ពុជា ..........................................

វគ្គទីបី : លទ្ធិប្រជាធិបតេយ្យ និង ពហុភាព ..........................................

វគ្គទីបួន : ច្បាប់អន្តរជាតិ ..........................................

វគ្គទីប្រាំ : ការអប់រំអ្នកបោះឆ្នោត ..........................................

## ★ សេចក្ដីណែនាំ

សៀវភៅនេះ គឺជាផ្នែកមួយនៃឯកសារមួយចំនួនស្ដីអំពីការអប់រំពលរដ្ឋ និង ការអប់រំអ្នកបោះឆ្នោត ដែលបានបង្កើតឡើងដោយវិទ្យាស្ថានប្រជាធិបតេយ្យជាតិ សំរាប់កិច្ចការអន្តរជាតិ (NDI) ដោយមានការជួយឧបត្ថម្ភគាំទ្រពីបណ្ដាអង្គការក្រៅរដ្ឋាភិបាលកម្ពុជាជាច្រើន ។ ឯកសារទាំងនេះ មានបំណងអោយប្រើប្រាស់ ដោយអ្នកបណ្ដុះបណ្ដាលនៅតាមបណ្ដាអង្គការក្រៅរដ្ឋាភិបាលនានា យកទៅបង្រៀនដល់ប្រជាពលរដ្ឋកម្ពុជាទាំងឡាយ អោយបានយល់ដឹងអំពីការអប់រំពលរដ្ឋ និង ការអប់រំអ្នកបោះឆ្នោត ។

## ***<u>គោលបំណងនៃការបណ្ដុះបណ្ដាល</u>***

គោលបំណងនៃការបណ្ដុះបណ្ដាលនេះ គឺផ្ដល់ការអប់រំពលរដ្ឋ និង ការអប់រំអ្នកបោះឆ្នោតដល់ប្រជាពលរដ្ឋកម្ពុជាទូទៅ ដោយហេតុថា ប្រជាពលរដ្ឋទាំងអស់ នឹងត្រូវចូលរួមបោះឆ្នោតថ្នាក់ឃុំ និង ថ្នាក់ជាតិនៅពេលឆាប់ៗខាងមុខនេះ ។ សៀវភៅនេះ ជួយណែនាំ ឬ ផ្ដល់ពត៌មានអោយប្រជាពលរដ្ឋបានយល់ដឹងអំពីលទ្ធិប្រជាធិបតេយ្យ សិទ្ធិពលរដ្ឋ ការទៅបោះឆ្នោត និង ការបោះឆ្នោតជ្រើសរើសអ្នកតំណាង ។

កត្តាដែលសំខាន់គឺអ្នកមាននាទីជាអ្នកបង្រៀនគេ ត្រូវតែបង្រៀនតាមលក្ខណៈអព្យាក្រឹត មិនលំអៀង ហើយក៏មិនត្រូវបង្ហាញថា ខ្លួនមានការពេញចិត្តទៅលើគណបក្សនយោបាយណាមួយ ឬក៏បេក្ខជនណាមួយនោះឡើយ ។ គំនិតចំបងដែលលើកមកនិយាយនៅក្នុងសៀវភៅនេះ គឺសុទ្ធតែជាគោលការណ៍មូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យទាំងអស់ ។

## ***<u>គោលដៅចំបងនៃការបណ្ដុះបណ្ដាល</u>***

លទ្ធផលសង្ឃឹមចង់បានពីវគ្គអប់រំពលរដ្ឋ និង អ្នកបោះឆ្នោតនេះគឺ ពលរដ្ឋកម្ពុជាទាំងឡាយនឹងមានលទ្ធភាពអាច ៖

- និយាយគ្នាអំពីតួនាទី និង កាតព្វកិច្ចរបស់ពលរដ្ឋម្នាក់ៗក្នុងលទ្ធិប្រជាធិបតេយ្យ
- យល់ច្បាស់ថា ហេតុអ្វីបានជាការទៅបោះឆ្នោតនេះមានសារៈសំខាន់
- យល់ដឹងអំពីដំណើរការបោះឆ្នោត និង ទំរង់ការនៃរបៀបបោះឆ្នោតទូទៅ
- បានដឹងឮ និង មានសេរីភាពជ្រើសរើសបេក្ខជន ឬ គណបក្សដែលខ្លួនពេញចិត្ត ។

| |
|---|
| វិទ្យាស្ថានប្រជាធិបតេយ្យជាតិសំរាប់កិច្ចការអន្តរជាតិ (NDI) គឺជាអង្គការក្រៅរដ្ឋាភិបាលមួយមិនរកចំណេញនោះទេ ហើយអង្គការនេះ ជាអង្គការមកពីប្រទេសសហរដ្ឋអាមេរិក ដែលធ្វើការងារសហការជាមួយបណ្ដាលអង្គការមហាជន គណបក្សនយោបាយ អង្គការនីតិបញ្ញត្តិ និង ជាមួយស្ថាប័នផ្សេងៗទៀតជាច្រើន ។ NDI បានចាប់បដិសន្ធិនៅឆ្នាំ ១៩៨៣ ។ អង្គការ NDI កំពុងបានបំពេញការងាររបស់ខ្លួនក្នុងប្រទេសចំនួនជាង ៦០ ប្រទេស ។ បេសកកម្មរបស់ NDI គឺជួយលើកស្ទួយថែរក្សា និង ពង្រឹងស្ថាប័នប្រជាធិបតេយ្យក្នុងប្រទេសដែលកំពុងតែផុសឡើងនូវលទ្ធិប្រជាធិបតេយ្យថ្មីៗ ។ |

### ***ការពិពណ៌នាអំពីឯកសារ***

ឯកសារសំរាប់យកទៅបណ្តុះបណ្តាលនេះ ត្រូវធ្វើឡើងយ៉ាងសាមញ្ញ ដើម្បីយកទៅប្រើប្រាស់បានងាយស្រួល ។ គេបានរៀបចំឯកសារនេះឡើង គឺសំដៅធ្វើអោយអ្នកបង្រៀន អាចមានមគ្គុទ្ទេសក៏ណែនាំមួយជំហានៗសំរាប់ធ្វើការបង្រៀន ឬអប់រំដល់ពលរដ្ឋ និង អ្នកបោះឆ្នោត តាមរយៈធ្វើការពិគ្រោះពិភាក្សាគ្នា និង តាមរយៈលំហាត់ណែនាំ ។ បន្ថែមទៅលើសៀវភៅហ្វឹកហ្វឺននេះ អ្នកហ្វឹកហ្វឺននៅមានផ្ទាំងរូបភាព ឯកសារសំរាប់ចែកអោយអ្នករៀន មានបែបបទសំរាប់វាយតំលៃវគ្គ និង មានឯកសារឯទៀតៗជាច្រើន ដែលពាក់ពន្ធ័នឹងវិស័យនេះ ។

★ ការរៀបចំរបស់អ្នកបង្រៀន

### ***ការរៀបចំធ្វើវគ្គបង្រៀន***

វគ្គបង្រៀនត្រូវតែរៀបចំអោយបានសាមញ្ញ យ៉ាងសមស្របហើយក៏មិនត្រូវធ្វើអ្វីមួយអោយមានសភាពស្មុគស្មាញដែរ ។ ប៉ុន្តែវាសំខាន់សំរាប់អ្នកបង្រៀនដើម្បីធ្វើគំរោង និង រៀបចំត្រៀមខ្លះៗមុនពេលទៅបើកវគ្គបង្រៀន ។ បើយើងរៀបចំ និង ធ្វើគំរោងបង្រៀនបានឆាប់ពេលណា នោះក៏ងាយស្រួលសំរាប់យើងចាត់ចែងដែរ តែបើយើងរៀបចំយឺតយ៉ាវពេកនោះ វាក៏អាចធ្វើអោយយើងមានការខុសឆ្គងច្រើនបានដែរ ។

### ***ជំហានទី១ : ការធ្វើគំរោងវគ្គបណ្តុះបណ្តាល***

ជំហានទី១ គឺត្រូវធ្វើគំរោងបង្រៀន ។ បញ្ជីសំរាប់ពិនិត្យការងារខាងក្រោមនេះ អាចជួយអោយយើងគិតគូរអំពីសំភារៈ និង អ្វីៗលំអិត ដែលយើងអាចត្រូវការវាសំរាប់រៀបចំ ។

*បញ្ជីត្រួតពិនិត្យការងារសំរាប់ធ្វើគំរោង*

*១. ពត៌មានអំពីអ្នកចូលរៀន*

- តើយើងត្រូវជ្រើសរើសមនុស្សដោយវិធីណាអោយមកចូលរៀនវគ្គនេះ ?
- តើយើងត្រូវអញ្ជើញមនុស្សដោយរបៀបណាអោយមករៀនវគ្គនេះ ?
- តើក្នុងមួយវគ្គៗ យើងត្រូវអោយមានមនុស្សប៉ុន្មាននាក់ ? យើងត្រូវតែគិតគូរនិងសំរេចអំពីចំនួនមនុស្សចូលរៀនមួយវគ្គៗ ដើម្បីអោយយើងងាយស្រួលបង្រៀនគេ ពីព្រោះថា យើងអោយមនុស្សច្រើនពេកមកចូលរៀនក្នុងមួយវគ្គៗនោះ វាអាចធ្វើអោយយើងពិបាក គិតគូរអំពីឯកសារទាំងអស់សំរាប់ចែក និង សំរាប់បង្រៀន ។
- តើអ្នកមករៀន ដឹងយល់អ្វីខ្លះអំពីលទ្ធិប្រជាធិបតេយ្យ ការបោះឆ្នោត និងការទៅបោះឆ្នោត ?
- តើអ្នកមករៀននោះចេះអក្សរ ឬ អត់ ?
- បើយើងចង់ប្តូរគំរោង ឬ កែប្រែការរៀបចំរបស់យើងវិញ តើយើងត្រូវប្រាប់ដល់អ្នករៀនយ៉ាងម៉េច ? កាលណាយើងរៀបចំការងារសំរាប់បង្រៀនបានរួចរាល់ហើយ យើងអាចប្រកាសអំពីពេលវេលា ប្រធានបទ ត្រូវបង្រៀន និង ពត៌មានចាំបាច់ឯទៀតៗ បិទនៅលើផ្ទាំង ក្រដាស

សំរាប់ប្រកាសមួយនៅទីកន្លែងមួយចំកណ្ដាលកន្លែងបង្រៀន ឬ ក៏នៅកន្លែងផ្សេងក្រៅពីកន្លែងបង្រៀន ។

*គន្លឹះសំខាន់* : យើងត្រូវទៅមើលស្ថានភាពភូមិដែលយើងត្រូវចូលទៅបង្រៀននោះ អោយបានច្រើនថ្ងៃ មុនពេលចាប់ផ្ដើមបង្រៀន ។ យើងត្រូវសាកសួរប្រធានភូមិ និង អ្នកភូមិថា តើយើងគួរបង្រៀននៅកន្លែងណា ហើយថាតើយើងផ្ដល់ពត៌មានដល់អ្នកភូមិតាមរបៀបណា អំពីការបណ្ដុះបណ្ដាលនេះ ។

២. *ទីកន្លែង*

- តើយើងចាំបាច់ត្រូវសុំច្បាប់អនុញ្ញាតពីប្រធានភូមិ ឬ ពីមន្ត្រីឯទៀតៗឬទេ ក្នុងការបើកបង្រៀននេះ ?
- តើយើងធ្វើការបង្រៀននេះនៅទីកន្លែងណា ? ទីកន្លែងដែលសមស្រប អាចបើកបង្រៀនបានមាននៅតាមសាលារៀន វត្តអារាម ឬ ក៏ធ្វើនៅតាមផ្ទះប្រធានភូមិតែម្ដង ។
- តើយើងមានប្រដាប់ប្រដាអ្វីខ្លះ ? ឧទាហរណ៍ ដូចជា ថាតើមានភ្លើងអគ្គិសនីឬទេ ? មានតុកៅអីឬទេ ? តើទីកន្លែងមានពន្លឺ និង ខ្យល់អាកាសចេញចូលគ្រប់គ្រាន់ឬទេ ? តើអ្នកមករៀនគ្រប់គ្នាស្ដាប់យើងឮទេ ?

៣. *សន្តិសុខ*

- តើអ្នកមានធ្វើទំនាក់ទំនងជាមួយនគរបាលដើម្បីធានាថា ទីកន្លែងដែលអ្នកទៅបង្រៀននោះ មានសុវត្ថិភាពឬទេ ?
- តើអ្នកចាំបាច់ត្រូវការអោយនគរបាលអមដំណើរអ្នកទៅ/មកទីកន្លែងបង្រៀននោះឬទេ ?
- តើអ្នកត្រូវអោយមានរៀបចំការពារសន្តិសុខពិសេសណាមួយឬទេ ? ឧទាហរណ៍ថា តើត្រូវមានយាមក្នុងពេលបង្រៀនឬទេ ?
- បើអ្នក ឬ អ្នកមករៀន មិនទុកចិត្ត ខ្លាចមានបញ្ហាសន្តិសុខកើតឡើងនោះ អ្នកត្រូវតែផាកការបង្រៀនវគ្គនោះសិន ។

បើមានបញ្ហាអសន្តិសុខកើតឡើងពេលកំពុងបង្រៀន យើងត្រូវទំនាក់ទំនងអង្គការរបស់យើង និងមន្ត្រីនគរបាល ឬ យោធាអោយឆាប់តាមលទ្ធភាព ។ អ្វីដែលសំខាន់បំផុត គឺត្រូវការពារអ្នករៀន និង ខ្លួនយើងកុំអោយមានគ្រោះថ្នាក់ ។ បើយើងដឹងថា យោធា ឬ នគរបាលជាប្រភពមូលហេតុដែលនាំអោយមានបញ្ហាអសន្តិសុខនេះ យើងត្រូវផាកការបង្រៀននេះជាបន្ទាន់ ។

៤. *ការដឹកជញ្ជូនមនុស្ស (អ្នកមករៀន)*

- តើអ្នកត្រូវការរៀបចំដឹកជញ្ជូនអ្នកមកចូលរៀនវគ្គនោះដែរឬទេ ?

- តើគេត្រប់គ្នាបានដឹងអំពីការរៀបចំដឹកជញ្ជូននោះឬទេ ? អ្នកត្រូវតែបិទប្រកាសប្រាប់អោយគេដឹងផងដែរអំពីបញ្ហានេះ គឺបិទជាមួយដំណឹងផ្សេងៗទៀត នៅកណ្តាលគេ ឬ ក៏នៅកន្លែងក្រៅពីកន្លែងបង្រៀននោះ ។

៥. *ការផ្តល់ចំណីអាហារ ភេសជ្ជៈ*

- តើអ្នកផ្តល់ទឹក ទឹកតែ កាហ្វេ នំ សំរាប់អោយអ្នកមករៀនហូបឬទេ ?

## ជំហានទី២ : រៀបចំពេលវេលា និង របៀបវារៈសំរាប់បង្រៀន

ត្រូវគិតគូរកំណត់យកកាលបរិច្ឆេទ និង ពេលវេលាសមស្របសំរាប់បើកវគ្គបង្រៀន ។ អ្នកត្រូវតែគិតគូរអំពីការងារប្រចាំថ្ងៃរបស់អ្នករៀន ហើយត្រូវតែរកមើលពេលវេលា និង ថ្ងៃណាដែលងាយស្រួលបំផុតសំរាប់អោយអ្នករៀនអាចមករៀនបាន ។ អ្នកត្រូវជ្រើសរើសរកពេលវេលាដែលអាចអោយអ្នករៀនទាំងនោះអាចត្រង់ត្រាប់ស្តាប់ និង ទទួលយកអ្វីដែលអ្នកបង្រៀនបានល ។

វគ្គអប់រំពលរដ្ឋ និង អ្នកបោះឆ្នោតនេះ គេគំរូវអោយបង្រៀនត្រឹមតែបីម៉ោងប៉ុណ្ណោះ ។

## ជំហានទី៣ : រៀបចំសំភារៈឯកសាររបស់អ្នក

អ្នកត្រូវរៀបចំទុកដាក់អោយបានស្រេច នូវអ្វីៗដែលអ្នកត្រូវការពេលបង្រៀន មុនពេលដែលវគ្គបង្រៀនចាប់ផ្តើម ។ អ្វីដែលអ្នកត្រូវការអោយមាន ដូចជា ៖

- ប្រដាប់ប្រដាសំរាប់អ្នកអប់រំពលរដ្ឋ និង អ្នកបោះឆ្នោត
- ឯកសារបន្ថែមសំរាប់អ្នកអប់រំពលរដ្ឋ និង អ្នកបោះឆ្នោត
- ផ្ទាំងរូបភាពធំៗ
- ឯកសារ (សៀវភៅតូចៗ) មានពត៌មានសំរាប់ចែកអោយអ្នករៀនមើល
- ពត៌មានដែលមានជាផ្ទាំង ឬ ក្រដាសធំៗ
- ប៊ិច (ម៉ាគ័រ) ធំៗសំរាប់សរសេរ
- សំភារៈផ្សេងៗទៀត ដែលអាចបង្ហាញអោយអ្នករៀនមើលយល់បាន ដូចជាប្រអប់ឆ្នោត ឬ ជាសន្លឹកឆ្នោតជាដើម សំរាប់ជាគំរូអោយគេមើល និង ចំណាំបាន ។

## ជំហានទី៤ : រៀបចំខ្លួនអ្នកផ្ទាល់

សៀវភៅនេះ ត្រូវបង្កើតឡើងសំរាប់ណែនាំអ្នកបង្រៀនអោយឈានមួយជំហានៗ ឆ្លងកាត់តាមការពិភាក្សាគ្នា និង តាមការបង្រៀនលំហាត់ណែនាំ ។ ដោយសារថា មនុស្សធំ ឬ មនុស្សចាស់ រៀនឆាប់ចេះតាមការអនុវត្តន៍ជាក់ស្តែងនោះ ដូច្នេះយើងមិនចាំបាច់រៀបចំមេរៀនដែងឡើយ ។

- អ្នកត្រូវត្រៀមបង្រៀនដោយអ្នកត្រូវអានសៀវភៅនេះ និង អានឯកសារផ្សេងៗថែមទៀត ដូចជា "ឯកសារបន្ថែមសំរាប់អ្នកអប់រំពលរដ្ឋ និង អ្នកបោះឆ្នោត" ។
- រួចអ្នកត្រូវគិតអំពីពលរដ្ឋដែលមករៀន ហើយសួរដោយខ្លួនអ្នកផ្ទាល់អំពីស្ថានភាពរបស់គេ ។

*អ្វីដែលអ្នកត្រូវយកមកពិចារណានោះមាន ៖*

- តើអ្នកដែលត្រូវមករៀននោះ គាត់មានការយល់ ឬ ចេះដឹងអំពីលទ្ធិប្រជាធិបតេយ្យ ការបោះឆ្នោត ការប្រើសន្លឹកឆ្នោត ការទៅបោះឆ្នោត និង ដឹងពីនយោបាយនៅកម្ពុជាដែរឬទេ ? បើសិនពួកគេមានចំណេះដឹង អ្នកត្រូវរៀបចំពួកគេជាក្រុមៗ ដើម្បីចែកចាយចំណេះដឹងទៅវិញទៅមក ។
- តើពួកគេចេះអាន ឬ សរសេរដែរឬទេ ? បើមិនចេះអាន ឬ សរសេរទេ អ្នកមិនត្រូវសរសេរលើផ្ទាំងក្រដាស ឬ ចែកចាយកូនសៀវភៅ ឬ ឯកសារមេរៀនទេ ។
- តើអ្នករៀនភាគច្រើនប្រកបការងារអ្វីខ្លះ ? អ្នកត្រូវប្រើឧទាហរណ៍អោយបាន ច្រើនដែលទាក់ទិនទៅនឹងបទពិសោធន៍ប្រចាំថ្ងៃរបស់ពួកគេ ។ បើសិនពួកគេជាអ្នកស្រែចំការ អ្នកអាចពន្យល់គេថា លទ្ធិប្រជាធិបតេយ្យ គឺជាដំណើរការមួយដែលអាចអោយពួកគេបោះឆ្នោតចំពោះមន្ត្រីណាដែលអាចជួយកែលំអប្រពន្ធ័ទឹកអោយបានប្រសើរ និងដឹកនាំផលិតផលរបស់ពួកគេមកកាន់ទីផ្សារបាន ។
- តើពួកគេចូលរួមបំរើសកម្មភាពនយោបាយឬទេឥឡូវនេះ ? យើងត្រូវដឹងការប៉ុនប៉ងរបស់សមាជិកគណបក្សនយោបាយណាមួយ ដែលប៉ងជះឥទ្ធិពលនយោបាយលើការបង្រៀន ។
- តើពួកគេធ្លាប់ចូលរួមបោះឆ្នោតជំនាន់អ៊ុនតាក់ ឆ្នាំ ១៩៩៣ ឬទេ ? បើធ្លាប់ត្រូវអោយពួកគេចែកចាយបទពិសោធន៍របស់គេថា តើពួកគេបានធ្វើអ្វីខ្លះ ? និង តើមានអ្វីដែលមិនអោយប្រជាពលរដ្ឋចូលរួមក្នុងការបោះឆ្នោត ?

ត្រូវគិតនូវឯកសារសំភារៈអ្វីខ្លះ ដែលអាចយកមកប្រើប្រាស់អោយមានប្រសិទ្ធិភាព នៅពេលអ្នកកំពុងហ្វឹកហាត់ ៖

- យើងត្រូវព្រៀងធ្វើកំណត់ត្រាទុក នូវអ្វីដែលជាឧទាហរណ៍ ដែលយើងត្រូវយកទៅលើកពន្យល់ ឬ ចង្អុលប្រាប់អ្នករៀនរបស់យើងពេលបង្រៀន ។ យើងត្រូវប្រើតែឧទាហរណ៍ណាដែលមានន័យសំរាប់អ្នករៀនរបស់យើងប៉ុណ្ណោះបានហើយ ម្យ៉ាងទៀត យើងត្រូវគោរព ទទួលស្គាល់ការចេះដឹង និង បទពិសោធន៍របស់អ្នករៀនដែលធ្លាប់មានព្រមទាំងយើងត្រូវព្យាយាមយកវាមកបញ្ចូលក្នុងកម្មវិធីបង្រៀនរបស់យើងទៀតផងដែរ ។
- បើអាចមាន យើងត្រូវតែប្រើបិចពណ៌ សំរាប់គូសសំគាល់លើសំណួរណាដែលយើងលើកយកមកសួរក្នុងពេលបង្រៀន ។ ហើយយើងត្រូវតែគូសបិចពណ៌ផ្សេងលើចំលើយដែលជាយោបល់សំរាប់អោយឆ្លើយ ។ ធ្វើដូច្នេះ វាធ្វើអោយយើងងាយស្រួលបញ្ជាក់ន័យរបស់វាដែលមាននៅក្នុងក្បួនពេលយើងបង្រៀន ។
- គិតគូររៀបចំពេលវេលាដែលយើងត្រូវការសំរាប់បង្រៀន ហើយនិងរៀបចំរបៀបវារៈសំរាប់បង្រៀន ដោយមើលការណែនាំផ្នែកបន្ទាប់ ។

- បើវគ្គបង្រៀននោះវាជាលើកទីមួយ យើងត្រូវអនុវត្តបង្រៀនផ្នែកនីមួយៗនៃកម្មវិធីបង្រៀនសាក ល្បងសិន ។

★ <u>ក្រមសីលធម៌/ច្បាប់ទូន្មានខ្លួនសំរាប់អ្នកបង្រៀន</u>

យើងត្រូវចងចាំថា មនុស្សជាច្រើនដែលយើងត្រូវបង្រៀននេះ គេមានការយល់ដឹងតិចណាស់អំពី គោលគំនិតនៃការបោះឆ្នោត និង អំពីលទ្ធិប្រជាធិបតេយ្យ ។ ដូច្នេះខាងក្រោមនេះ គឺជាខ្លឹមសារខ្លះៗ ដែល យើងត្រូវចងចាំពេលរួមការងារជាមួយគ្នា ៖

I. ត្រូវអនុវត្តការងាររបស់យើងអោយមានយុត្តិធម៌ មិនមានលំអៀង មិនមានគំនិតប្រកាន់បក្សពួក ត្រូវមានឯករាជ្យលើមតិនយោបាយផ្ទាល់ខ្លួនរបស់យើង ។ ឧទាហរណ៍ : បើមាននរណាម្នាក់ សួរយើងអំពីគណបក្សណាមួយ ឬ បេក្ខជនណាមួយនោះ យើងត្រូវព្យាយាមឆ្លើយទៅគេវិញ តាមវិធីមួយដែលសំដៅលើគ្រប់គណបក្ស ឬ បេក្ខជនទាំងអស់ ។ ឧទាហរណ៍ : មាន មនុស្សម្នាក់និយាយថា "ខ្ញុំមានការខ្វល់ខ្វាយណាស់ ព្រោះមានសមាជិករបស់គណបក្ស X ធ្វើ ការបង្ខិតបង្ខំអ្នកបោះឆ្នោតនៅក្នុងស្រុកខ្ញុំ" ។ ដូច្នេះយើងត្រូវពន្យល់អ្នករៀនវិញថា គេចង់បោះ ឆ្នោតអោយនរណាក៏បានដែរ អោយតែគេពេញចិត្ត គ្មានគណបក្សណាមួយមកបង្ខំថា ត្រូវ បោះអោយអ្នកនេះ ឬ អ្នកនោះឡើយ ។

II. យើងមានចិត្តជាមិត្ត សុភាពរាបសារ គួរសម និងអត់ធ្មត់ អត់ធនជានិច្ច គឺមិនត្រូវបណ្តែត បណ្តោយខ្លួនយើងអោយទៅប្រកែកវែកញែកជាមួយប្រជាពលរដ្ឋ ឬក៏អោយអារម្មណ៍យើងទៅ ជាម៉ូម៉ៅខឹងសម្បារនោះទេ ហើយក៏មិនត្រូវប្រកាន់យកតែទស្សនៈផ្ទាល់របស់យើងដែរ ។

III. ត្រូវធ្វើអ្វីៗអោយទៀងទាត់តាមពេលវេលាកំណត់ ហើយត្រូវរៀបចំបង្រៀនអោយមានពេលវេលា សមហេតុសមផល ព្រមទាំងត្រូវអនុវត្តតាមកាលបរិច្ឆេទអោយបានខ្ជាប់ខ្ជួន និង តាមពេល វេលាដែលបានលៃលកទុកមក ។ ឧទាហរណ៍ថា បើយើងបើកបង្រៀននៅតាមភូមិណាមួយ វាអាចមានការពិបាកនឹងធ្វើការបង្រៀននៅពេលល្ងាច យើងមិនត្រូវរំខានពេលវេលាពេលថ្ងៃ របស់អ្នករៀនដែរ ។ មុនពេលកំណត់បង្រៀន យើងត្រូវតែសួរអ្នករៀនថា តើពេលណាដែល ជាពេលសមស្របបំផុតសំរាប់ពួកគេអោយមករៀនបាននោះ ។

IV. យើងត្រូវតែរៀបចំត្រៀមអោយបានលជានិច្ច ពីព្រោះថា វាមានសារៈសំខាន់ណាស់ដែលយើង ត្រូវតែធ្វើការងារយើងអោយបានល្អប្រសើរ ។ ឧទាហរណ៍ : យើងត្រូវតែប្រាកដថា យើង ត្រូវតែចូលរួមរាល់វគ្គបង្រៀនអ្នកអប់រំអោយបានគ្រប់វគ្គ និងបានអានរាល់ឯកសារទាំងអស់ដែល ពាក់ព័ន្ធដើម្បីអោយយើងចេះដឹងប្រាកដ អំពីរបៀបការបោះឆ្នោត និង ច្បាប់បោះឆ្នោត បទ បញ្ញត្តិ ។ យើងត្រូវតែសួរជានិច្ចនូវអ្វីដែលយើងយល់ពុំបានច្បាស់លាស់ ។

V. យើងត្រូវតែទាក់ទាញមនុស្សគ្រប់រូបអោយគេចូលរួមរៀនសូត្រ ហើយក៏មិនត្រូវបណ្តែតបណ្តោយ អោយជនណាម្នាក់និយាយច្រើន ឬ មានយោបល់ច្រើនតែឯងដែរ ។ បើសិនជាមាននរណា ម្នាក់មានយោបល់ច្រើនតែម្នាក់ឯងនោះ យើងត្រូវថ្លែងអំណរគុណអ្នកនោះដែលគាត់បានខិតខ

-

បញ្ចេញគំនិតរបស់គាត់មករួមជាមួយយើង ប៉ុន្តែយើងត្រូវពន្យល់វិញថា ទាំងយើង និងទាំងអ្នកដទៃទៀតដែលមករៀននោះ ក៏ចង់ឮមតិផ្សេងៗទៀតដែរ ។ យើងត្រូវធ្វើយ៉ាងណាព្យាយាមប្រឹងប្រែងធ្វើអោយអ្នកមករៀនគ្រប់ៗរូប ចូលរួមមានមតិយោបល់អោយបានគ្រប់ៗគ្នា ។

VI. យើងត្រូវតែគោរពវ័យអាយុរបស់មនុស្ស និង គោរពប្រពៃណីរបស់អ្នកស្រុក ទោះជាមានអ្នកខ្លះមកពីតំបន់ ឬ ក្រុមជនជាតិភាគតិចណាមួយក៏ដោយ ហើយក៏ត្រូវគោរពការចេះដឹង បទពិសោធន៍របស់អ្នកមករៀន និង ព្យាយាមយកគំនិតសមូហភាពមកអនុវត្តផងដែរ ។

VII. យើងត្រូវតែនិយាយអោយច្បាស់ៗ ហើយឮៗដើម្បីអោយអ្នករៀនគ្រប់ៗរូប បានយល់ និងឮយើងនិយាយ ។ ឧទាហរណ៍ : ចូរអ្នកសួរប្រជាពលរដ្ឋនៅខាងក្រោយគេ ប្រសិនបើពួកគេអាចឮ អាចស្តាប់អ្នកបាន ។ ប្រសិនបើស្តាប់មិនបាន មិនស្តាប់ឮនោះ អ្នកអាចនិយាយអោយខ្លាំងៗ ផ្លាស់ទីកន្លែងឈរ ឬ រៀបកៅអីក្នុងបន្ទប់ឡើងវិញ ។

VIII. ចូរចងចាំថា យើងកំពុងតែធ្វើអ្វីមួយដល់ពលរដ្ឋខ្មែរឯទៀតៗ ដែលជាមិត្តរួមសញ្ជាតិរបស់យើង ដូច្នេះយើងចាំបាច់ត្រូវតែជួយដល់គេគ្រប់ៗគ្នា ដែលកំពុងតែត្រូវការជំនួយជួយជ្រោមជ្រែងពីយើង ។

IX. យើងត្រូវប្រើគំនិតផ្តួចផ្តើមរបស់យើង ជួយដោះស្រាយបញ្ហានានាដែលអាចកើតមាននៅក្នុងពេលបង្រៀនរបស់យើង ហើយយើងក៏ត្រូវយល់កាលៈទេសៈ សម្របសម្រួលវគ្គបង្រៀនរបស់យើងអោយវាប្រព្រឹត្តទៅបានសមស្របនឹងសេចក្តីត្រូវការចង់បានរបស់អ្នករៀនដែរ ។ បើអ្នករៀនភាគច្រើនបំផុតចង់បានពេលវេលាច្រើន ជាពេលដែលយើងបានលៃទុកនោះ យើងត្រូវតែប្រឹងប្រែងបើកឱកាសទៅតាមចំណូលចិត្តរបស់ពួកគេ តែយើងក៏អាចបន្ថយពេលពីប្រធានបទផ្សេងៗវិញដែរ តែធ្វើយ៉ាងណាត្រូវតែមានការឯកភាពអោយបានច្រើនបំផុតពីអ្នករៀន ។

X. យើងត្រូវតែរ៉ាប់រងទទួលខុសត្រូវគ្រប់ពេលវេលា ព្រមទាំងត្រូវរក្សាទុករាល់កំណត់ហេតុទាំងអស់របស់អ្នករៀនគ្រប់ៗរូប និង ការវាយតំលៃរបស់គេ ។ បើមានអ្នកសួរយើង ហើយយើងឆ្លើយមិនកើតនោះ យើងត្រូវតែស្រាវជ្រាវរកចំលើយអោយបានត្រឹមត្រូវ ហើយសឹមឆ្លើយនៅពេលក្រោយ ។ បើយើងប្រើប្រាស់សំភារៈ ឬ ឧបករណ៍អ្វីមួយដែលពុំមែនជារបស់យើង ៗ ត្រូវតែថែទាំរក្សារបស់នោះអោយល្អ រួចប្រគល់របស់នោះទៅអោយម្ចាស់ដើមគេវិញ ។ ធ្វើយ៉ាងណាត្រូវផ្តល់ពត៌មានទំនាក់ទំនងសំរាប់ខ្លួនយើង និងដល់អង្គការរបស់អ្នកផងដែរ ។

## លទ្ធផលរកឃើញរបស់ក្រុមមុខសញ្ញាស្ទង់មតិ

កាលពីខែ មេសា ឆ្នាំ ១៩៩៦ NDI បានដឹកនាំក្រុមមុខសញ្ញាស្ទង់មតិចំនួន ១០ ក្រុមនៅកម្ពុជាក្នុងកិច្ចប្រឹងប្រែងមួយ ដើម្បីអោយបានដឹងពីការយល់ដឹងស៊ីជំរៅរបស់ប្រជាជនកម្ពុជា អំពីការបោះឆ្នោត និងអំពីលទ្ធិប្រជាធិបតេយ្យ ។ គេបានរៀបចំមនុស្សជាក្រុមៗ ដើម្បីអោយបានដឹងអំពីគំនិតរបស់បុរស ស្ត្រី អ្នករស់នៅទីក្រុង កម្មករនៅជនបទ និង ពលរដ្ឋខ្មែរដែលមានការអប់រំរៀនសូត្រ ។ លទ្ធផលរកឃើញរបស់ក្រុម

មុខសញ្ញាស្ទង់មតិ បាន[illegible] [illegible]ងអពទស្សនៈរបស់ពលរដ្ឋក[illegible] [illegible]ចំពោះការបោះឆ្នោត ឬ ការប្រើសន្លឹកឆ្នោត /ទៅបោះឆ្នោត និង ចំពោះលទ្ធិប្រជាធិបតេយ្យ ព្រមទាំងចំពោះក[illegible]ប្រែប្រួលក្នុងជីវភាពរស់នៅរបស់គេ ចាប់ តាំងពីការបោះឆ្នោតកាលពីឆ្នាំ ១៩៩៣ មក ។ លទ្ធផលសំខាន់ៗ ដែលត្រូវរកឃើញបានរៀបរាប់ជូននៅខាង ក្រោមនេះហើយ អាចមានសារៈប្រយោជន៍សំរាប់យើង ពេលយើងជួយណែនាំអ្នករៀនក្នុងឱកាសដែលយើង បើកបង្រៀនគេ ។

➢ មនុស្សគ្រប់រូប សុទ្ធតែចង់បានអោយមានសន្តិភាពដូចៗគ្នា និង ចង់អោយមានជីវភាពរស់នៅល្អប្រសើរ ដោយមានលទ្ធិប្រជាធិបតេយ្យ ។

នៅពេលដែលមនុស្សគ្រប់រូបមានគំនិតថា លទ្ធិប្រជាធិបតេយ្យ ត្រូវការអោយមានការគោរពច្បាប់ នោះអ្នកចូលរួមទាំងអស់នោះ ក៏បានមើលឃើញព្រមៗគ្នាថា លទ្ធិប្រជាធិបតេយ្យ គឺជាមធ្យោបាយចំបងមួយ ឆ្ពោះទៅរកសន្តិភាព និង ជីវភាពរស់នៅល្អប្រសើរដែរ ។ តទៅនេះ គឺជាឧទាហរណ៍ខ្លះៗដែលគេបាន លើកឡើង ៖

- លទ្ធិប្រជាធិបតេយ្យ ដែលមានអនុភាពលើក្រុមគ្រួសារខ្ញុំនោះ គឺយើងមិនត្រូវមានសង្គ្រាមនៅក្នុង ប្រទេសជាតិរបស់យើង ឬ ក៏ក្នុងចំណោមប្រជាជនយើងទេ ។
- សង្គមដែលមានប្រជាធិបតេយ្យ មានន័យថា ជាប្រទេសជាតិដែលមានសេរីភាព និង សន្តិភាព ហើយក៏គ្មានសង្គ្រាមដែរ ។
- កាលណាយើងនិយាយអំពីប្រទេសសេរី គឺយើងចង់មានន័យថា ប្រជាពលរដ្ឋនៃប្រទេសនោះ មានសិទ្ធិរស់នៅរកស៊ីទីណាក៏បាន គឺយើងត្រូវតែមានសិទ្ធិសេរីភាពក្នុងការដើរហើរ (ធ្វើដំណើរ) និងប្រកបរបររកស៊ីដើម្បីជីវភាពរស់នៅ ។

<u>អ្វីដែលយើងគួរធ្វើ</u>

កាលណាយើងនិយាយអំពីសារៈប្រយោជន៍ ឬ សារៈសំខាន់នៃលទ្ធិប្រជាធិបតេយ្យ និង ការបោះ សន្លឹកឆ្នោត/ការទៅបោះឆ្នោតជ្រើសរើសតំណាងខ្លួន យើងគួរចងចាំអោយបានថា មនុស្សគ្រប់ៗរូប ត្រូវមាន សិទ្ធិធ្វើដូច្នោះស្មើៗគ្នា និង មានសន្តិសុខព្រមទាំងមានលទ្ធភាពធ្វើការរកស៊ីចិញ្ចឹមជីវិតដូចៗគ្នាផងដែរ ។ នេះ សរបញ្ជាក់អោយឃើញច្បាស់ថា ប្រជាពលរដ្ឋពុំមែនបាន ឬ មានសិទ្ធិសេរីភាពនេះដោយសារតែគេអោយ ប៉ុណ្ណោះនោះទេ ។ ពលរដ្ឋខ្មែរមានភារកិច្ចទទួលខុសត្រូវមើលថែរក្សាលទ្ធិប្រជាធិបតេយ្យ ហើយអាច អនុវត្តលទ្ធនេះ តាមរយៈធ្វើការបោះឆ្នោតជ្រើសរើសតំណាងខ្លួន និង ចូលរួមជួយធ្វើអោយការបោះឆ្នោត នោះ មានលក្ខណៈសេរី និង មានយុត្តិធម៌ ។ ការចូលរួមធ្វើអ្វីមួយជាទៀតទាត់ អោយជយជានាអោយ មានដំណោះស្រាយរកសន្តិភាពលើជម្លោះនយោបាយផ្សេងៗ ហើយនិងជួយធ្វើអោយមានស្ថេរភាពទៀតផង ។

➢ ការទុកចិត្តលើស្ថាប័ននានារបស់ខ្មែរនៅមានកំរិតទាប

គេបានពិនិត្យឃើញថា មានការទុកចិត្តតិចតួចណាស់ទៅលើស្ថាប័នធំៗនានា ដូចជា វិរៈជនឧនយោបាយ គណបក្សនយោបាយ យោធា ប្រពន្ធ័តុលាការ នគរបាល និង ប្រពន្ធ័ផ្សព្វផ្សាយពត៌មាន ។ គេតែងសង្កេតឃើញថា មានមេដឹកនាំនយោបាយតិចគ្នាណាស់ ដែលនិយាយអ្វីៗចំពោះ ឬ ដើម្បីប្រជាពលរដ្ឋរបស់ខ្លួន ហើយចំណែកឯរដ្ឋាភិបាលវិញ ភាគច្រើនៗតែធ្វើអ្វីៗ (អើពើ) តែលើរឿងរ៉ាវរបស់ខ្លួន ឬក៏តែលើផលប្រយោជន៍នៃអំណាចតែប៉ុណ្ណោះ ។ មានតែអង្គការក្រៅរដ្ឋាភិបាលខ្មែរនានាតែប៉ុណ្ណោះ ដែលភាគច្រើនគេបានមើលឃើញថា ជាអង្គការពុំសូវមានឥទ្ធិពល ឬ អំណាចនោះ ច្រើនតែមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន ហើយក៏មិនត្រូវគ្រប់ដណ្តប់ត្រួតត្រាលើដោយមេដឹកនាំនយោបាយណាមួយនោះឡើយ ។

## *អ្វីដែលយើងគួរធ្វើ*

ដោយសារថា យើងនេះកំពុងតែបំរើការងារមួយដែលជាផ្នែកមួយក្នុងការងារចំរុះរបស់អង្គការក្រៅរដ្ឋាភិបាលនោះ យើងត្រូវតែចាប់ផ្តើមពីចំណុចមួយដែលអាចធ្វើអោយអ្នកមករៀនមានជំនឿមកលើយើងក្នុងពេលបង្រៀន ។ យើងត្រូវតែឆ្លៀតយកឱកាសនោះ ដើម្បីបញ្ជាក់អោយគេឃើញថា យើងមានយុត្តិធម៌មិនលំអៀងទេ ។ ហើយយើងក៏គួរតែបញ្ជាក់អោយគេយល់ពីសារៈសំខាន់របស់ចលនាអង្គការក្រៅរដ្ឋាភិបាលដែលជាចលនាមានសន្តិភាពជួយធ្វើអោយមានការកែប្រែក្នុងសង្គមកម្ពុជាផងដែរ ។ លទ្ធិប្រជាធិបតេយ្យទាំងឡាយ ចាំបាច់ត្រូវតែមានស្ថាប័នដែលមានស្វ័យភាព ឬ ក៏មានសេរីភាពឯករាជ្យម្ចាស់ការ ពុំមែននៅក្រោមការកាន់កាប់ត្រួតត្រាដោយរដ្ឋាភិបាលឡើយ ធ្វើដូច្នេះទើបប្រជាពលរដ្ឋមានមធ្យោបាយអោយបញ្ចេញមតិយោបល់របស់គេបានចំពោះមន្ត្រីបំរើការក្នុងជួររដ្ឋាភិបាល ។ បញ្ហាអង្គការក្រៅរដ្ឋាភិបាលទាំងឡាយ អាចធ្វើជាកន្លែងបញ្ចេញមតិសមូហភាពរបស់ពលរដ្ឋ សំរាប់ប្រាប់ដំណឹងដល់រដ្ឋាភិបាលអំពីអ្វីដែលពលរដ្ឋពេញចិត្ត និងអ្វីដែលគេមិនពេញចិត្ត ។ ការដែលអាចមានស្ថាប័ននានាក្នុងក្នុងសង្គមជនស៊ីវិលដ៏មាំទាំ ដូចជាមានអង្គការក្រៅរដ្ឋាភិបាល មានសហជីពពលកម្ម និង មានអង្គការសាសនាបាននោះ ។អាចជាការចាប់ផ្តើមមានតុល្យភាពអំណាចក្នុងកម្ពុជាជាប្រាកដ ។

លើសពីនេះទៀត ការបោះឆ្នោតជ្រើសរើសតំណាង គឺជាការផ្តល់ឱកាសមួយអោយប្រជាពលរដ្ឋប្រាប់ដល់បណ្តាមន្ត្រីដែលខ្លួនបានជ្រើសរើសនោះថា លោកមន្ត្រីទាំងនោះបាន ឬ ពុំបានបំរើសាធារណៈជនបានល ឬ ក៏អត់ ព្រោះថា ក្នុងលទ្ធិប្រជាធិបតេយ្យ បើពលរដ្ឋបាត់ជំនឿលើអ្នកដឹកនាំរបស់គេហើយនោះ គេអាចបោះឆ្នោតទំលាក់មេដឹកនាំនោះអោយចេញពីអំណាចបាន ។

➢ អ្នកមកចូលរួមមានទស្សនៈទាបអំពីលទ្ធិប្រជាធិបតេយ្យ

ប្រជាពលរដ្ឋកម្ពុជា ជាមធ្យមយល់ថា តួនាទីរបស់គេដែលគេមានក្នុងលទ្ធិប្រជាធិបតេយ្យនោះ មានកំរិតតិចតួចណាស់ គឺប្រជាពលរដ្ឋទាំងនោះក្រៅពីមិនបានយល់ថា ខ្លួនឯងជាអ្នកមានតួនាទីសំខាន់ មានសិទ្ធិមានភារកិច្ចទទួលខុសត្រូវលើបញ្ហានោះ គេបែរជាជឿថា ភារកិច្ចទទួលខុសត្រូវនាំមកនូវការកែប្រែសង្គម និង

កសាងលទ្ធិប្រជាធិបតេយ្យ នោះវាអាស្រ័យតែលើមេដឹកនាំរបស់គេ និងនៅលើសហគមន៍អន្តរជាតិតែប៉ុណ្ណោះទៅវិញ ។

*អ្វីដែលយើងគួរធ្វើ*

យើងត្រូវតែបញ្ជាក់ប្រាប់គេអោយបានច្បាស់ថា រដ្ឋាភិបាលដែលមានប្រជាធិបតេយ្យ គឺជារដ្ឋាភិបាល "របស់ប្រជាពលរដ្ឋ និង សំរាប់ប្រជាពលរដ្ឋ" ។ មានន័យថា ប្រជាពលរដ្ឋ ដូចអ្នកដែលបានមកចូលរៀនវគ្គនេះដែរនោះ គឺជាប្រភពរបស់អំណាចក្នុងសង្គមប្រជាធិបតេយ្យ ។ ពលរដ្ឋគ្រប់រូបត្រូវតែរៀនសូត្រអោយ បានយល់ដឹងអំពីច្បាប់ អំពីសិទ្ធិរបស់ខ្លួន ហើយគេក៏ត្រូវតែអនុវត្តសិទ្ធិរបស់គេនោះដែរ គឺគេត្រូវតែធ្វើការកែប្រែអ្វីដែលត្រូវការកែប្រែ ។ ថ្វីបើបណ្ដាមេដឹកនាំ និង សហគមន៍អន្តរជាតិ អាចជួយបានខ្លះក៏មែនពិត តែជួនកាលក៏គេពុំបានដឹងអំពីអ្វីដែលប្រជាពលរដ្ឋចង់បាន ឬ ក៏ត្រូវការនោះដែរ ។ ពលរដ្ឋគ្រប់រូប គឺជាអ្នកដែលត្រូវតែលើកអំពីអាទិភាពនានា សំរាប់អោយរដ្ឋាភិបាលរបស់ខ្លួនអនុវត្ត ។ បើរដ្ឋាភិបាលមិនបានធ្វើអ្វីមួយជួយដោះស្រាយបញ្ហាដែលប្រជាពលរដ្ឋភាគច្រើនយល់ថា សំខាន់ ចាំបាច់ទេនោះ ប្រជាពលរដ្ឋអាចជ្រើសរើសរដ្ឋាភិបាលថ្មីមកជំនួសពេលបោះឆ្នោតលើកក្រោយៗ ។

# ជំពូកទី ១
# សេចក្តីណែនាំអំពីការបើកវគ្គបង្រៀន

## <u>សេចក្តីផ្តើម</u>

<u>ពេលចាប់ផ្តើម</u>

..... ***<u>នាទី</u>***

ធ្វើយ៉ាងណារៀបចំអ្នកមករៀនបានអង្គុយស្រួល ហើយអាចស្តាប់យើងឮច្បាស់ ។ បន្ទាប់មកយើងត្រូវឧទ្ទេសនាមអោយគេស្គាល់យើងដោយប្រាប់គេ ៖

១. អំពីឈ្មោះយើង

២. អង្គការដែលយើងធ្វើការ

៣. គោលបំណងរបស់អង្គការយើង និង អំពីថាតើអង្គការយើងនឹងរួមចំណែកយ៉ាងណាខ្លះក្នុងការងារបោះឆ្នោត

៤. ហើយនិងប្រាប់ពីហេតុផលដែលយើងចង់ធ្វើការអប់រំដល់អ្នកបោះឆ្នោតនេះ

*<u>ឧទាហរណ៍</u>* : យើងត្រូវនិយាយថា : "ខ្ញុំឈ្មោះ {...} និង អង្គការឈ្មោះ {...} ខ្ញុំជាសមាជិករបស់ {ក្រុមការងារចំរុះរបស់យើង} ។ អង្គការរបស់ខ្ញុំមានការចាប់អារម្មណ៍ខ្លាំង ចង់ជួយដល់ពលរដ្ឋខ្មែរអោយត្រៀមខ្លួនសំរាប់ធ្វើការបោះឆ្នោតនៅពេលឆាប់ៗខាងមុខនេះ ដោយយើងខ្ញុំត្រូវតែជួយអប់រំដល់ពលរដ្ឋទូទៅ និង ដល់អ្នកដែលត្រូវចូលរួមបោះឆ្នោត ឬ អ្នកបោះឆ្នោត ។ អង្គការរបស់យើងខ្ញុំ ចង់បើកវគ្គបង្រៀននេះ ដោយអង្គការនេះចង់អោយពលរដ្ឋកម្ពុជាគ្រប់ៗរូប យល់ដឹងថាតើលទ្ធិប្រជាធិបតេយ្យមានន័យដូចម្តេចខ្លះ ហើយពលរដ្ឋគ្រប់ៗរូប ត្រូវទៅចូលរួមបោះសន្លឹកឆ្នោតទៅបោះឆ្នោត នៅពេលបោះឆ្នោតនាពេលខាងមុខនេះ" ។

យើងក៏ត្រូវណែនាំអោយអ្នកមករៀនបានស្គាល់ផងដែរ បើនៅទីនោះមានអ្នកសង្កេតការណ៍ ឬ អ្នកដែលជាធនធានមនុស្សសំរាប់ជួយដល់វគ្គបង្រៀន ដែលគេមានមុខចូលរួមនៅពេលនោះដែរ ហើយក៏ត្រូវពន្យល់ប្រាប់អ្នករៀនអោយបានបានច្បាស់លាស់ផងដែរថា តើហេតុអ្វីបានជាអ្នកទាំងនោះមានវត្ត_មាននៅពេលបង្រៀនដែរនោះ ។

*ត្រូវពន្យល់អ្នករៀនពីគោលបំណងនៃវគ្គបង្រៀនដោយត្រូវនិយាយថា :*

១. អង្គការអាមេរិកកាំង ដែលមានឈ្មោះថា វិទ្យាស្ថានប្រជាធិបតេយ្យជាតិសំរាប់កិច្ចការអន្តរជាតិ ឬ "NDI" នេះដោយមានការជួយជ្រោមជ្រែងពីបណ្តាអង្គការក្រៅរដ្ឋាភិបាលកម្ពុជានានាជាច្រើនផងនោះ បានបង្កើតអោយមានកម្មវិធីមួយ អប់រំពលរដ្ឋ និង អ្នកបោះឆ្នោត ។

២. កម្មវិធីនេះ បានបង្កើតអោយមាននៅតាមគ្រប់បណ្តាអង្គការទាំងអស់ដែលធ្វើការងារខាងសិទ្ធិមនុស្ស និង ដែលពាក់ព័ន្ធជាមួយការងារបោះឆ្នោតនៅកម្ពុជា ។

៣. អង្គការរបស់យើងខ្ញុំ ដែលមកជួយបើកបង្រៀនដល់បងប្អូនប្រជាពលរដ្ឋនៅពេលនេះ គឺមកពីអង្គការយើងខ្ញុំ ចង់ជួយដល់ពលរដ្ឋកម្ពុជាទាំងអស់អោយបានយល់ដឹងច្រើនថែមទៀត អំពីការទៅបោះឆ្នោតក្នុងពេលបោះឆ្នោតនៅថ្ងៃខាងមុខ និង អំពីសិទ្ធិរបស់យើងម្នាក់ៗក្នុងនាមជាពលរដ្ឋខ្មែរ ។

***<u>គោលដៅចំបងរបស់វគ្គបណ្តុះបណ្តាលនេះ</u>***

ត្រូវពន្យល់ប្រាប់អ្នកមកស្តាប់អោយបានយល់ដឹងអំពីគោលដៅបឋម (ចំបង) នៃវគ្គបណ្តុះបណ្តាលនេះ ដោយនិយាយថា ៖ លទ្ធផលដែលយើងនឹងទទួលបានអំពីវគ្គអប់រំ ពលរដ្ឋ និង អ្នកបោះឆ្នោតនេះ គឺពលរដ្ឋខ្មែរគ្រប់រូបនឹងអាច ៖

- យល់ដឹងអំពីតួនាទី និងភារកិច្ចរបស់យើងម្នាក់ៗ ជាពលរដ្ឋរស់នៅក្នុងសង្គមប្រជាធិបតេយ្យ។ ឧទាហរណ៍ : អ្នកមកចូលរួមវគ្គរៀនសូត្រនេះ នឹងចេញពីកន្លែងរៀននេះទៅផ្ទះវិញ ដោយនាំយកទៅជាមួយខ្លួននូវការយល់ដឹងច្រើនថែមទៀតអំពីសិទ្ធិ អាស្រ័យធម្មនុញ្ញរបស់ខ្លួន ហើយនិងយល់ដឹងអំពីវិធីដែលខ្លួនត្រូវយកសិទ្ធិនេះទៅអនុវត្ត ឬ ប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួន ។
- យល់ដឹងបានថា តើហេតុអ្វីបានជាការបោះឆ្នោតនោះមានសារៈសំខាន់ ។ ពេលរៀនចប់ អ្នករៀនម្នាក់ៗ នឹងអាចដឹងថា ការបោះឆ្នោត គឺជាផ្នែកដ៏សំខាន់មួយនៃលទ្ធិប្រជាធិបតេយ្យ ហើយលទ្ធិនេះ ជាមធ្យោបាយមួយអាចជួយនាំអោយគណបក្សនយោបាយផ្សេងៗ អាចដោះស្រាយបញ្ហាខ្វែងគំនិតគ្នាបានដោយសន្តិវិធី និង មានសន្តិភាព ។
- យល់ដឹងអំពីដំណើរការបោះឆ្នោត និង ប្រពន្ធ័នៃការបោះឆ្នោត ។ អ្នកចូលរួមរៀនត្រូវយល់ថា ពួកគេមានសិទ្ធិបោះឆ្នោតដោយសំងាត់ ហើយពួកគេអាចបោះឆ្នោតអោយអ្នកណាមួយដែលពួកគេចង់ ។
- យល់ដឹងថា ត្រូវមានការជ្រើសរើសតាមចិត្តចង់បាន ក្នុងពេលបោះឆ្នោត គឺរើសបេក្ខជន ឬ គណបក្សណាដែលខ្លួនពេញចិត្ត *ឧទាហរណ៍* : អ្នករៀនត្រូវចេញពីរៀនវគ្គនេះទៅផ្ទះវិញ ដោយនៅមានគំនិតចង់ដឹងថែមទៀតអំពីស្ថានភាពរបស់បេក្ខជន និង របស់គណបក្សលើបញ្ហាដែលពាក់ព័ន្ធណាមួយ ហើយគាត់ក៏ត្រូវយល់ដឹងផងដែរថា សន្លឹកឆ្នោតដែលគាត់បោះនោះ គឺជាសន្លឹកឆ្នោតសំងាត់ឥតមាននរណាដឹងថា គាត់បោះអោយអ្នកណា ឬបេក្ខជនណានោះឡើយ ។

***របៀបវារៈ***

ត្រូវចងុលប្រាប់អ្នកស្តាប់ទៅលើផ្ទាំងប្រដាសធំៗ ឬ ក៏ទៅលើខ្លឹមសារដែលបញ្ជាំងអោយពួកគាត់មើលនោះ អោយគាត់ឃើញដឹងអំពីរបៀបវារៈ ដែលយើងបានរៀបចំទុកមកស្រាប់ (មានបង្ហាញជូននៅទំព័របន្ទាប់នេះ) ។ យើងត្រូវអានរបៀបវារៈទាំងនេះអោយគាត់ស្តាប់ ហើយពន្យល់សង្ខេប អោយគាត់បានឮអំពីចំណុចនីមួយៗ ដែលយើងនឹងលើកនៅពេលបង្រៀនខ្លឹមសាររបស់មេរៀន ។

| ពេលវេលា | ថេរវេលា | សកម្មភាព |
|---|---|---|
| - | - | ផ្នែកទី ១ :<br>• ណែនាំអោយដឹងអំពីវគ្គរៀនសូត្រ<br>• អ្នកចូលរួមធ្វើឧទ្ទេសនាមអោយគេស្គាល់ខ្លួន |
| - | - | ផ្នែកទី ២ :<br>• បង្ហាញរូបភាពលទ្ធិប្រជាធិបតេយ្យ<br>• ជំរាបអ្នកចូលរួមអោយដឹងថា តើអ្វីទៅជាលទ្ធិប្រជាធិបតេយ្យ ? |
| - | - | • ជំរាបអ្នកចូលរួមអោយដឹងអំពីលក្ខណៈនៃលទ្ធិប្រជាធិបតេយ្យ |
| - | - | • *លំហាត់* : អត្ថប្រយោជន៍នៃលទ្ធិប្រជាធិបតេយ្យ |
| - | - | • ជំរាបអ្នកចូលរួមអោយបានដឹងយល់អំពីលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា |
| - | - | ផ្នែកទី ៣ :<br>• ជំរាបអ្នករៀនអោយដឹងថា តើអ្វីទៅជាការបោះឆ្នោត ? |
| - | - | • *លំហាត់* : សារៈសំខាន់នៃការបោះឆ្នោត |
| - | - | • ជំរាបអ្នករៀនអោយបានដឹងថា តើអ្នកបោះឆ្នោតមានសិទ្ធិអ្វីខ្លះ ? |
| - | - | • *លំហាត់* : តើយើងអាចធ្វើយ៉ាងម៉េច ដើម្បីធ្វើអោយការបោះឆ្នោតនោះ វាប្រព្រឹត្តទៅដោយសេរី និង មានយុត្តិធម៌ |
| - | - | សេចក្តីសន្និដ្ឋាន និង ធ្វើការវាយតំលៃដល់វគ្គរៀនសូត្រនេះ |

***ចំណាំ***

យើងត្រូវគិតអំពីអ្នកមករៀនថា តើគេមានកំរិតយល់ដឹងប៉ុណ្ណា និង គិតអំពីផ្នែកសំខាន់បំផុតនៃឯកសារ ខ្លឹមសារមេរៀន ដែលយើងនឹងបង្រៀនគេនោះ ។ បើយើងមានពេលពុំគ្រប់គ្រាន់ទេនោះ ត្រូវអាចចំលងលំហាត់ខ្លះៗដែលវាពុំសូវសំខាន់ទាក់ទងនឹងការបង្រៀនរបស់យើង ។

***ទំរង់ការទូទៅ***

ត្រូវនាំអោយអ្នករៀនប្រមូលអារម្មណ៍ផ្តោតទៅលើផ្ទាំងក្រដាសធំៗ ដែលយើងបានសរសេរចំណុចនានា ពាក់ពន្ធ័ការបង្រៀនរបស់យើង ។ រួចអានចំណុចនីមួយៗ និងពន្យល់គាត់អំពីទំរង់ការងារសំរាប់រៀន ដោយនិយាយថា ៖

- ➢ អ្នករៀនទាំងអស់ ត្រូវតែខិតខំមានយោបល់ក្នុងពេលរៀនសូត្រ
- ➢ អ្នករៀនទាំងអស់ត្រូវដឹងថា ពេលនេះខ្លួនមានសិទ្ធិសេរីភាពនិយាយស្តី ឬ ក៏សួរសំណួរណាមួយ ដែលពាក់ពន្ធ័នឹងការរៀនសូត្រនេះ ។
- ➢ អ្នករៀនទាំងអស់ត្រូវចេះគោរពសិទ្ធិអ្នកដទៃពេលដែលគេនិយាយ ឬ ក៏មានមតិយោបល់
- ➢ សុំកុំអោយមានអ្នករៀនណាម្នាក់និយាយ ឬ មានយោបល់តែម្នាក់ឯងពេក ។

***<u>ការធ្វើឧទ្ទេសនាមរបស់អ្នកមករៀនម្នាក់ៗ</u>***

ត្រូវពន្យល់ថា ឥឡូវនេះអ្នកមករៀនម្នាក់ៗ ត្រូវឆ្លៀតពេលណែនាំអោយគេឯងបានស្គាល់គាត់ តែមិនត្រូវប្រើពេលវេលាយូរពេកទេ ។

| |
|---|
| *<u>គន្លឹះសំខាន់</u>* : បើមានពលរដ្ឋណាម្នាក់ពិតជាមិនចង់ណែនាំអោយគេស្គាល់ខ្លួនគាត់ទេនោះ យើងក៏មិនត្រូវបង្ខំអោយគាត់និយាយដែរ គឺយើងត្រូវតែរំលងគាត់ទៅអ្នក បន្តបន្ទាប់ទៀតវិញ ។ |

*ត្រូវអញ្ជើញអោយអ្នករៀនម្នាក់ៗនិយាយយ៉ាងសង្ខេបថា :*

- ខ្ញុំឈ្មោះ
- ខ្ញុំមកពី (ភូមិ, ក្រុម, ... ?)
- មូលហេតុដែលខ្ញុំចង់មករៀន ឬ មកស្តាប់នេះ គឺមកពីខ្ញុំ ...

យើងត្រូវធ្វើយ៉ាងណាអោយអ្នកមករៀនគ្រប់ៗរូប បានមានឱកាសនិយាយ ។

កាលណាអ្នកមករៀនណែនាំខ្លួនចប់អស់គ្នាហើយ យើងត្រូវប្រាប់ទៅពួកគាត់ថា បន្តបន្ទាប់ទៅទៀតនេះ យើងនឹងពន្យល់ពួកគាត់អោយយល់ដឹងពីគោលគំនិតសំខាន់ៗ និង គោលការណ៍សំខាន់ៗរបស់លទ្ធិប្រជាធិបតេយ្យ ។ ដាច់ខាតយើងត្រូវតែសួរពួកគាត់ក្រែងពួកគាត់មានសំណួរមុនពេលយើងចាប់បន្តទៅផ្នែកបន្ទាប់ៗទៀត ។



# ជំពូកទី ២
# តើលទ្ធិប្រជាធិបតេយ្យជាអ្វី ?

## តើអ្វីទៅដែលហៅថា លទ្ធិប្រជាធិបតេយ្យ ?

### I. លំហាត់ : រៀបរាប់រូបភាពអំពីលទ្ធិប្រជាធិបតេយ្យ

..... **នាទី**

បង្ហាញអ្នករៀនអោយឃើញរូបគំនូជញ្ជីងមួយដែលមានស្ត្រីនៅម្ខាង និង បុរសនៅម្ខាង ។ រួចសួរអ្នករៀនថា តើគាត់បានឃើញអ្វីខ្លះនៅក្នុងរូបភាពនោះ ។

*យើងត្រូវជួយអ្នករៀនអោយលើកមតិឡើង ដូចជា ៖*

- រូបខាងឆ្វេង គឺជាស្ត្រីក្រីក្រម្នាក់
- រូបខាងស្តាំ គឺជាបុរសម្នាក់មានទ្រព្យសម្បត្តិ
- បុរសនោះមានកាន់កាតាប "វ៉ាលី" ហើយគាត់ប្រហែលជាអ្នកធ្វើការនៅការិយាល័យ
- ស្ត្រីនោះស្លៀកពាក់តាមប្រពៃណីគាត់ ហើយគាត់ធ្វើការងារម្យ៉ាងបែប "ថោកទាប" ។
- ជញ្ជីងដែលអ្នកទាំងពីរឈរលើនេះ មានទំងន់ស្មើគ្នា

*យើងត្រូវសួរអ្នករៀនដូចតទៅនេះ ៖*

- តើក្នុងរូបទាំងពីរនេះ មានរូបមួយណាដែលមើលទៅមានភាពចំរើនជាងគេ ?
- តើក្នុងរូបទាំងពីរនេះ មានរូបមួយណាដែលមើលទៅមានអំណាចជាងគេ ? ហេតុអ្វី?
- តើជញ្ជីងនេះតំណាងអោយអ្វីដែរ ?
- តើរូបនេះចង់សរបញ្ជាក់អោយយើងឃើញថា មានរូបមួយគ្រាន់បើជាងរូបមួយទៀតឬ?

អ្នករៀនត្រូវតែសង្កេតអោយបានយល់ន័យថា រូបភាពនេះ គឺចង់បង្ហាញអំពីតំណែងសំខាន់ដែលអាចធ្វើអោយមានវប្បធម៌មួយមានលទ្ធិប្រជាធិបតេយ្យ ។ តំណែងទាំងនេះមួយចំនួនមាន ៖

១. ការសំរេចក្នុងការគ្រប់គ្រង គឺធ្វើឡើងតាមការគ្រប់គ្រងដោយមតិភាគច្រើន ប៉ុន្តែទស្សនៈនៃប្រជាពលរដ្ឋភាគតិច ត្រូវបានគេគោរព និង ការពារ ។ មានន័យថា ឧទាហរណ៍ : គណបក្សដែលបានទទួលសំលេងតិច អាចមានកៅអីចំនួនតិចដែរ នៅក្នុងសភាជាតិ តែក៏នៅអាចមានសិទ្ធិរួមចំណែករាល់ការងារទាំងអស់សំរាប់ដឹកនាំប្រទេសជាតិដែរ ។

២. លទ្ធិប្រជាធិបតេយ្យ ធានាអោយពលរដ្ឋទាំងអស់មានសិទ្ធិគ្រប់ៗគ្នា ពុំមែនមានតែអ្នកមានអំណាចផុតគេ ឬ ក៏មានចំនួនច្រើននោះទេ ។ ទាំងកសិករ បុគ្គលិកមន្ត្រីរាជការ មនុស្សចាស់ (ប្រុស) ស្ត្រីយក្មេងៗ ប្រធានឃុំ សមាជិកសភាជាតិ ទាំងអស់គ្នាដែលសុទ្ធតែជាពលរដ្ឋដូចគ្នានោះ ត្រូវតែមានសិទ្ធិស្មើៗ (ដូចៗ) គ្នាទាំងអស់ ។

៣. យើងត្រូវតែអនុគ្រោះដល់អ្នកដែលបញ្ចេញទស្សនៈខុសពីយើង ដូចជាសមាជិកនានារបស់គណបក្សនយោបាយឯទៀតៗជាដើម ។ល។ ព្រោះថា យើងសុទ្ធតែជាពលរដ្ឋខ្មែរទាំងអស់គ្នា ហើយសុទ្ធតែមានសិទ្ធិបញ្ចេញទស្សនៈ និង មានសិទ្ធិបញ្ចេញទស្សនៈដូចៗគ្នាទាំងអស់ ។

៤. ត្រូវគោរពមនុស្សដែលមានដើមកំណើត និង កាន់សាសនាផ្សេងពីយើង ដូចជាជនជាតិវៀតណាម និង ចាម ជាដើម ។ល។ ពលរដ្ឋកម្ពុជាសុទ្ធតែមានសាវតាផ្សេងៗពីគ្នាច្រើន តែយើងទាំងអស់គ្នា សុទ្ធជាមនុស្សមានសិទ្ធិដូចៗគ្នា ។

## II. ផ្តល់ពត៌មានអំពី : តើលទ្ធិប្រជាធិបតេយ្យជាអ្វី ?

..... ***នាទី***

ណែនាំអ្នករៀនអោយបានយល់ដឹងពីប្រធានបទទូទៅអំពីអ្វីដែលតែងតែនិយាយ មានន័យលើលទ្ធិប្រជាធិបតេយ្យ ដោយលើកនូវចំណុចដូចខាងក្រោមនេះ ៖

- លទ្ធិប្រជាធិបតេយ្យ គឺជាទំរង់មួយនៃការដឹកនាំដែលប្រជាជនជ្រើសរើសមេដឹកនាំរបស់គេ និង តែងតាំងអោយអ្នកដឹកនាំទាំងនោះ ទទួលខុសត្រូវលើអ្វីដែលគេត្រូវដឹកនាំខ្លួនដែលជាប្រជារាស្ត្រ។
- បើប្រជាពលរដ្ឋមិនពេញចិត្តអ្នកដឹកនាំទាំងនោះ ពួកគេអាចជ្រើសរើសអ្នកដឹកនាំថ្មីផ្សេងទៀត ។

| |
|---|
| <u>*ភារកិច្ចទទួលខុសត្រូវ*</u> មានន័យថា មន្ត្រីរដ្ឋាភិបាល ត្រូវតែពន្យល់ ឬ ថ្លឹងថ្លែងសកម្មភាពរបស់ខ្លួនអោយត្រូវចិត្ត ឬ ការចង់បានរបស់សាធារណៈជនទូទៅ ។ |

យើងត្រូវអញ្ជើញអោយអ្នករៀនស្ម័គ្រចិត្តឡើងមកបកស្រាយ ឬ អោយនិយមន័យអំពីរដ្ឋាភិបាលតាមបែបប្រជាធិបតេយ្យ ។ បើយើងមានក្រដាសផ្ទាំងធំៗ ឬក៏ក្តារខៀន យើងត្រូវសរសេរយោបល់របស់អ្នកបកស្រាយនោះអោយអ្នកដទៃឃើញ ។

យើងត្រូវលើកនិយាយនូវអ្វីដែលជាការផ្តល់ជាយោបល់ច្បាស់លាស់ជាក់លាក់របស់អ្នករៀន រួចសុំអោយពួកអ្នករៀនផ្តល់គំនិតទូទៅលើយោបល់ទាំងនោះ ។ យើងត្រូវព្យាយាមនាំអ្នករៀនអោយគាត់ផ្តល់និយមន័យដែលត្រឹមត្រូវ ឬ ក៏ក្បែរៗត្រូវក៏បាន បើអាចទៅរួច ។ បើអ្នករៀនគេលើកពីឈ្មោះប្រទេសនានា ដែលគេយល់ថា ប្រទេសទាំងនោះ មានលទ្ធិប្រជាធិបតេយ្យនោះ យើងត្រូវព្យាយាមពន្យល់គាត់ថា ហេតុអ្វីបានជាគេមានទស្សនៈដូច្នោះ ។ យើងចាំបាច់ត្រូវតែជំរាបដល់អ្នករៀនអោយបានជ្រាបថា ពាក្យថាប្រជាធិបតេយ្យមាននិយមន័យច្រើនណាស់ ប៉ុន្តែនិយមន័យមួយដែលគេបានឃើញមានជាទូទៅនោះគឺ "ការគ្រប់គ្រងដោយមតិ

ភាគច្រើន ។ មានន័យថា រដ្ឋាភិបាលត្រូវតែធ្វើអ្វីៗទៅតាមបំណងប្រាថ្នារបស់ពលរដ្ឋភាគច្រើនបំផុតដែលគេចង់បាន ។

| |
|---|
| *គន្លឹះសំខាន់* : នៅខាងក្រោយឯកសារនេះ យើងនឹងឃើញមានឯកសារ បន្ថែមមួយទៀត ដែលមានពត៌មានបន្ថែមអំពីរដ្ឋាភិបាលតាមបែបប្រជាធិបតេយ្យ ។ យើងត្រូវអានផ្នែកទី៣ ដើម្បីត្រៀមរៀបចំបង្រៀនជំពូកទី ២ ។ |

### III. ការរៀបរាប់ជំរាបពត៌មានអំពី : លក្ខណៈនៃលទ្ធិប្រជាធិបតេយ្យ

..... ***នាទី***

យើងត្រូវពន្យល់អ្នករៀនថា ថ្វីបើរចនាសម្ព័ន្ធ និង ការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យនេះ វាតែងមានការខុសគ្នាច្រើនទៅតាមប្រទេសនីមួយៗក៏ដោយ ក៏លទ្ធិនេះភាគច្រើនបំផុតវាមានលក្ខណៈរួមគ្នាដែរ ដូចជា ៖

១. មន្ត្រីធំៗ (ថ្នាក់ខ្ពស់ៗ) ត្រូវតែជ្រើសរើសដោយការបោះឆ្នោតអោយកាន់តំណែងដែលធ្វើឡើងតាមអាណត្តិបោះឆ្នោតកំណត់ឡើងជាទៀងទាត់ ។

២. ច្បាប់នេះ ត្រូវអនុវត្តដោយតុលាការឯករាជ្យ ហើយនិងមន្ត្រីរាជការសាធារណៈត្រូវតែគោរពច្បាប់នេះ ដូចជា ពលរដ្ឋសាមញ្ញដូច្នោះដែរ ។

៣. មនុស្សពេញវ័យស្ទើរតែទាំងអស់ សុទ្ធតែមានសិទ្ធិបោះឆ្នោត ដោយសន្លឹកឆ្នោតសំងាត់ (អាចលើកលែងករណីអ្នកពិការប្រាជ្ញា ស្មារតី ឬ ក៏អ្នកទោសដែលជាប់មន្ទីរឃុំឃាំងចេញ) ។

៤. ពលរដ្ឋស្ទើរតែគ្រប់ៗគ្នាមានសិទ្ធិបើក ឬ ដឹកនាំការិយាល័យនយោបាយ (លើកលែងតែអ្នកមានអាយុ និង ទីលំនៅមិនទាន់សមស្របតាមច្បាប់កំណត់) ។

៥. ពលរដ្ឋទាំងអស់មានសិទ្ធិបោះពុម្ពផ្សព្វផ្សាយសារពត៌មាន និង ផ្សព្វផ្សាយពត៌មាននានា តាមប្រពន្ធ័ផ្សព្វផ្សាយពត៌មាន ហើយនិងគេមានសិទ្ធិទទួលពត៌មានពីប្រភពផ្តល់ពត៌មានជាច្រើនៗថែមទៀតផងដែរ ។

៦. ពលរដ្ឋគ្រប់រូបមានសិទ្ធិនឹងបង្កើតគណបក្សនយោបាយ និង អង្គការឯករាជ្យមានសមាគម និងក្រុមឯទៀតៗ ដែលមានផលប្រយោជន៍ ។

៧. ពលរដ្ឋមានសិទ្ធិរិះគន់អ្នកដឹកនាំរដ្ឋាភិបាល ដោយពុំមានការភិតភ័យពីការដាក់ទោសពៃអ្វីឡើយ ។

ត្រូវតែទុកពេលវេលាអោយអ្នករៀនបានសួរសំណួរ និង ជជែកវែកញែកអំពីគំនិតដែលយើងទើបតែបានពន្យល់ប្រាប់គាត់រួចមកនោះ ។

យើងត្រូវពន្យល់ផងដែរថា ក្នុងលទ្ធិប្រជាធិបតេយ្យ មនុស្សយើងមានសិទ្ធិច្រើនណាស់ តែក៏មានភាតព្វកិច្ច និង ភារកិច្ចទទួលខុសត្រូវច្រើណាស់ដែរ ។

សួរអ្នករៀនថា : នៅក្នុងលទ្ធិប្រជាធិបតេយ្យ តើពលរដ្ឋមានភារកិច្ចទទួលខុសត្រូវអ្វីខ្លះ ? យើងត្រូវសរសេរយោបល់ឆ្លើយតបរបស់អ្នករៀនដាក់លើក្រដាសផ្ទាំងធំៗ ។ យើងត្រូវជួយអោយអ្នករៀនផ្តុំយោបល់ឯកភាពគ្នាអោយបានខ្លីៗ សំរាប់សរសេរអំពីភារកិច្ចទទួលខុសត្រូវនោះ ។

| |
|---|
| រដ្ឋធម្មនុញ្ញកម្ពុជាមានចែងជាច្រើននូវកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ ។ សូមមើលផ្នែកទី៣ នៃឯកសារបន្ថែម ។ |

*រួចមកអោយយោបល់ថា ៖*

- កាតព្វកិច្ចបឋមរបស់ពលរដ្ឋ គឺចូលរួមជាមួយរដ្ឋាភិបាល ។ ការបោះឆ្នោតនេះ គ្រាន់តែជាវិធីដែលពលរដ្ឋចូលរួមជាមួយរដ្ឋាភិបាលតែប៉ុណ្ណោះ ។
- ពលរដ្ឋម្នាក់ៗ ក៏ត្រូវតែអប់រំខ្លួនគេផងដែរ អំពីបញ្ហានានាដែលប្រឈមមុខនឹងរដ្ឋាភិបាល ដើម្បីអោយខ្លួនអាចបោះសន្លឹកឆ្នោតតាមការដែលខ្លួនបានដឹង ។
- ពលរដ្ឋគ្រប់រូបរស់នៅក្នុងសង្គមប្រជាធិបតេយ្យ ក៏ត្រូវតែមានការអត់ធ្មត់ ត្រាប្រណីដល់អ្នកដទៃដែលមានទស្សនៈខុស ឬ ផ្ទុយពីខ្លួនយើងនោះដែរ ។ ហើយទន្ទឹមនោះទៀត ក៏យើងត្រូវមានចិត្តសហការ ដើម្បីអោយអាចសំរេច និង ទទួលយកបានដោយមនុស្សភាគច្រើន ។

| |
|---|
| *<u>គន្លឹះសំខាន់</u>* : ពេលយើងបង្រៀនផ្នែកនេះ ត្រូវចងចាំការសង្កេតរបស់សញ្ញាដែលបង្ហាញអោយយើងដឹងថាតើពលរដ្ឋកម្ពុជាមានអារម្មណ៍ដូចម្តេចអំពីលទ្ធិប្រជាធិបតេយ្យ ។ |

យើងត្រូវសុំអោយអ្នករៀនគិតរកអោយឃើញថា គេមានភារកិច្ចទទួលខុសត្រូវអ្វីខ្លះទៀត ក្នុងនាមគេជាពលរដ្ឋនោះ ។ ហើយយើងក៏ត្រូវសរសេរយោបល់ទាំងនោះ ទុកលើក្រដាសផ្ទាំងធំៗ រួចសង្ខេបយោបល់ទាំងនេះឡើងវិញពេលធ្វើលំហាត់នេះចប់ ។

## IV. <u>លំហាត់</u> : <u>អត្ថប្រយោជន៍នៃលទ្ធិប្រជាធិបតេយ្យ</u>

..... ***<u>នាទី</u>***

ប្រាប់អ្នករៀនអោយឆ្លៀតពេលមួយនាទី គិតអំពីការជជែកគ្នាដែលយើងនឹងធ្វើរួចអំពីលទ្ធិប្រជាធិប_តេយ្យ ។ យើងត្រូវសុំអោយអ្នករៀនម្នាក់ៗគិតអំពីចំណុច ១ ឬ ២ នៃអត្ថប្រយោជន៍របស់លទ្ធិប្រជាធិប_តេយ្យ ។ ពលរដ្ឋដែលចូលរួមរៀនវគ្គនោះ ត្រូវតែត្រៀមខ្លួនបញ្ចេញយោបល់ទាំងនេះដាក់រួមជាមួយអ្នករៀនដទៃទៀត ។

ត្រូវប្រាប់អោយពលរដ្ឋមករៀននោះស្ម័គ្រចិត្តបញ្ចេញយោបល់របស់គេ ហើយយើងក៏ត្រូវព្យាយាមធ្វើអោយអ្នករៀនម្នាក់ៗ បានបញ្ចេញយោបល់និយាយពីនេះពីនោះខ្លះៗផង ។

រាល់គំនិតយោបល់ដែលអ្នករៀនលើកឡើងត្រូវកត់លើក្រដាសផ្ទាំងធំៗទាំងអស់ ។

បន្ទាប់ពីអ្នករៀនបានលើកយោបល់អស់ហើយ យើងត្រូវនាំពួកគាត់ពិភាក្សាគ្នា លើយោបល់ទាំងនោះ ។ ត្រូវប្រឹងប្រែងបង្រួមយោបល់អោយឯកភាពគ្នា ដើម្បីធ្វើកណត់ងោយបានខ្លីអំពីអត្ថប្រយោជន៍ទាំងនោះ ។

*យោបល់ខ្លះៗដែលយើងអាចជំរាបអ្នករៀននោះមាន ៖*

- ការពារសិទ្ធិសេរីភាព
- ការអប់រំប្រជាពលរដ្ឋអោយយល់ដឹងអំពីកិច្ចការសាធារណៈរបស់គេ
- ការផ្លាស់ប្តូររដ្ឋាភិបាលដោយសន្តិវិធី

<u>*គន្លឹះសំខាន់*</u> : ចូរចងចាំខ្លឹមសារលទ្ធផលរបស់ក្រុមមុខសញ្ញាស្ទង់មតិ ។ ពលរដ្ឋគ្រប់ៗរូបគិតថាលទ្ធិប្រជាធិបតេយ្យ ធ្វើអោយមានសន្តិភាព និងការរស់នៅមានភាពប្រសើរ ។ យើងពន្យល់អ្នករៀនអោយយល់ថា លទ្ធិប្រជាធិបតេយ្យជាដំណើរការមួយសំរាប់ដោះស្រាយជំលោះនានាដោយសន្តិវិធី ។ ឧទាហរណ៍ : ការបោះឆ្នោតធ្វើអោយមនុស្សអាចជ្រើសរើសមេដឹកនាំរបស់ខ្លួន ដោយគ្មានការវាយតប់ ឬ ប្រយុទ្ធគ្នាទៅវិញទៅមកឡើយ ។
លទ្ធិប្រជាធិបតេយ្យនេះ ក៏ធ្វើអោយមនុស្សអាចបោះឆ្នោតជ្រើសរើសបេក្ខជនដែលជួយធ្វើអោយជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួនបានល្អប្រសើរផងដែរ ។ ឧទាហរណ៍ : ប្រជាពលរដ្ឋអាចបោះឆ្នោតបេក្ខជនដែលជួយកសាងសាលារៀន កែលំអប្រព័ន្ធថែទាំសុខភាព ក្នុងភូមិរបស់ពួកគេ ។ បើមន្ត្រីណាមួយធ្វើការមិនឆ្លើយតបតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនោះ ប្រជាពលរដ្ឋអាចបោះឆ្នោតអោយអ្នកដទៃផ្សេងទៀតក៏បាន ។

## V. ជំពូកទីមានអំពី : លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា

..... <u>***ទាទី***</u>

យើងត្រូវពន្យល់គេថា តាំងតែពីឆ្នាំ ១៩៩៣ ប្រទេសកម្ពុជាបាននឹងកំពុងធ្វើអោយមានការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យជាបណ្តើរៗ ។

<u>*ឧទាហរណ៍*</u> : មាន ៖

- ពហុបក្ស /គណបក្សច្រើន : ក្នុងលទ្ធិប្រជាធិបតេយ្យប្រជាជន មានសិទ្ធិបង្កើតគណបក្សនយោបាយ ហើយនិងប្រកួតប្រជែងយកតំណែងជាសាធារណៈ ។ កាលពីជំនាន់អ៊ុនតាក់ ពេលដែលកម្ពុជាបានធ្វើការបោះឆ្នោតមួយ ដើម្បីជ្រើសរើសសភាធម្មនុញ្ញមួយនោះ ពេលនោះមានគណបក្សដល់ទៅ ២០ គណបក្សបានចូលរួមបោះឆ្នោត ។
- ការបោះឆ្នោតសេរី និង មានយុត្តិធម៌ : ការបោះឆ្នោតដែលមានលក្ខណៈសេរី និង យុត្តិធម៌ គឺជាមុខងារដ៏សំខាន់មួយនៃលទ្ធិប្រជាធិបតេយ្យ ។ ដូច្នេះ ការបោះឆ្នោតសេរី និង មានយុត្តិធម៌នេះ គឺមានន័យថា ប្រជាពលរដ្ឋទាំងអស់ ពលរដ្ឋគ្រប់រូប ត្រូវតែមានសិទ្ធិបោះឆ្នោតដោយពុំមានការបង្ខិតបង្ខំ ឬក៏កៀបសង្កត់អោយបោះអោយអ្នកនេះ ឬ គណបក្សនេះ/នោះ ក្រៅតែពី

ជម្រើសផ្ទាល់របស់ខ្លួននោះឡើយ ។ របៀបបោះឆ្នោតត្រូវតែយុត្តិធម៌ត្រឹមត្រូវ ។ ឧទាហរណ៍ គណបក្ស និងបេក្ខជនទាំងអស់ត្រូវតែផ្តល់ឱកាសអោយប្រជាពលរដ្ឋទៅបោះឆ្នោតដោយសមរម្យ។

> *គន្លឹះសំខាន់* : យើងមិនត្រូវបណ្តែតបណ្តោយអោយមានការជជែកវែកញែកគ្នាអំពីផលប្រយោជន៍ ឬ ការមិនមានប្រយោជន៍របស់គណបក្សណាមួយ ឬ ក៏របស់អ្នកនយោបាយណាមួយនៅក្នុងប្រទេសកម្ពុជានោះឡើយ ។ យើងត្រូវតែសង្កត់ធ្ងន់ថា ពលរដ្ឋគ្រប់ៗរូប ត្រូវតែធ្វើការសំរេចចិត្តដោយខ្លួនឯងរៀងៗខ្លួន អំពីគណបក្ស និង បេក្ខជនដែលគេយល់ថា ល្អបំផុតសំរាប់បោះឆ្នោតអោយនោះ ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាធានាអោយមានរដ្ឋាភិបាលប្រជាធិបតេយ្យ ។ ទាំងនេះគឺជាសិទ្ធិដែលត្រូវបានការពារនៅក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជា ៖

* ពលរដ្ឋកម្ពុជា មានសិទ្ធិសេរីភាពបញ្ចេញមតិយោបល់របស់ខ្លួន សេរីភាពសារពត៌មាន សេរីភាពខាងបោះពុម្ពផ្សព្វផ្សាយ និង មានសេរីភាពក្នុងការប្រជុំ ... [ជំពូក ៣ (៤១)] ។
* ពលរដ្ឋកម្ពុជា មានសិទ្ធិបង្កើតសមាគម និង គណបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ [ជំពូក ៣ (៤២)] ។
* ពលរដ្ឋកម្ពុជារាល់ៗរូប ត្រូវគោរពច្បាប់រដ្ឋធម្មនុញ្ញ និង គោរពច្បាប់ [ជំពូក ៣ (៤៩)] ។
* ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។ ពលរដ្ឋកម្ពុជាជាម្ចាស់ជោគវាសនាប្រទេសជាតិរបស់ខ្លួន ។ អំណាចទាំងអស់ ជារបស់ប្រជាពលរដ្ឋ ... [ជំពូក ៤ (៥១)] ។
* អំណាចតុលាការ ជាអំណាចឯករាជ្យ ហើយអំណាចតុលាការ ធានាអនាគត និង ការពារសិទ្ធិសេរីភាពរបស់ពលរដ្ឋ ... [ជំពូក ៩ (១០៩)] ។ ព្រះមហាក្សត្រជាអ្នកធានាអោយមានឯករាជ្យភាព នៃអំណាចតុលាការ ... [ជំពូក ៩ (១១៣)] ។
* ការពិនិត្យសើរើ ឬ វិសោធនកម្មច្បាប់រដ្ឋធម្មនុញ្ញ មិនអាចធ្វើទៅបានទេ បើការកែប្រែទាំងនោះមានការប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស និង របបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញនោះ ... [ជំពូក ១៣ (១៣៤)] ។
* ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចបានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលអំពីសិទ្ធិមនុស្ស និង កតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងអស់ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ... [ជំពូក ៣ (៣១)] ។
* ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និង តាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ... [ជំពូក ១ (១)] ។

> ឯកសារបន្ថែមរបស់អ្នកអប់រំ មានរបៀបចំលំអិតច្រើនទៀត ស្តីអំពីរដ្ឋធម្មនុញ្ញរបស់កម្ពុជាក្នុងផ្នែកទី ៣ ។
> សិទ្ធិទាំងឡាយដែលបានធានានៅក្នុងរដ្ឋធម្មនុញ្ញត្រូវតែអនុវត្ត បើវាពិតជាមានន័យចំពោះពលរដ្ឋ។ ត្រូវសួរអ្នករៀន ក្រែងគេជឿថា សិទ្ធិទាំងនេះកំពុងតែត្រូវអនុវត្តឥឡូវនេះ ។

យើងត្រូវតែផ្តល់ពេលអោយអ្នករៀនបានសួរសំណួរ និង ពិភាក្សាគ្នាអំពីគំនិតយោបល់ទាំងឡាយដែលយើងទើបតែបានបង្រៀនរួច ។ យើងត្រូវសួរអ្នករៀនក្រែងគេបានឃើញមានភស្តុតាងអ្វីមួយអំពីគំនិតយោបល់ទាំងនេះ ក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់គេ ។

សេចក្តីសន្និដ្ឋាន អំពីជំពូក (ម៉ូឌុល) ទាំងនោះ ដោយលើកឡើងថា ការបោះឆ្នោត គឺជាវិធីមួយសំរាប់អោយពលរដ្ឋអនុវត្តសិទ្ធិប្រជាធិបតេយ្យរបស់គេ ។ ហើយផ្នែកបន្តបន្ទាប់ នឹងផ្តល់ពត៌មានអំពីសេចក្តីលំអិតនៃការបោះឆ្នោត ។

# ជំពូកទី ៣
# ការអប់រំអ្នកបោះឆ្នោត

## I. ការបង្រៀនអំពី : តើអ្វីទៅដែលហៅថា ការបោះឆ្នោត ?

..... ***នាទី***

សុំអោយរៀនឆ្លើយ នឹងសំណួរនេះ : តើការបោះឆ្នោតជាអ្វី ? យើងត្រូវសរសេរចំលើយរបស់អ្នករៀនលើក្រដាសផ្ទាំងធំៗ ឬ លើក្តារខៀន ។ ហើយយើងក៏ត្រូវចង្អុលប្រាប់អ្នករៀននូវចំលើយស្រដៀងៗ ដែលគេធ្លាប់ដឹងផងដែរ ។ ចូរចងចាំថា : នេះគឺជាឱកាសរបស់យើង ដែលត្រូវយល់ដឹងអំពីការយល់ដឹងរបស់អ្នករៀនដែលគាត់មានស្តីអំពីការបោះឆ្នោត ។

> *គន្លឹះសំខាន់* : នៅខាងក្រោយឯកសារនេះ យើងឃើញឯកសារមួយបន្ថែមទៀតដែលមានពត៌មាន និង ឧទាហរណ៍ជាច្រើនថែមទៀត ស្តីអំពីការអប់រំអ្នកបោះឆ្នោត ។ យើងត្រូវតែអានផ្នែកទី ៥ ដើម្បីត្រៀមរៀបចំខ្លួនយើងបង្រៀនជំពូក (ម៉ូឌូល) ទី ៣ ។

*យើងត្រូវពន្យល់គេថា :*

នៅក្នុងប្រទេសកាន់ប្រជាធិបតេយ្យ ប្រជាពលរដ្ឋត្រូវតែអនុវត្តសិទ្ធិបោះឆ្នោតរបស់គេអោយបានទៀងទាត់នៅក្នុងការបោះឆ្នោតដោយសេរី និង មានយុត្តិធម៌ ។

- មនុស្សទាំងអស់ (ពលរដ្ឋគ្រប់រូប) ត្រូវមានសេរីភាពបោះឆ្នោតជ្រើសរើសមនុស្ស ឬ គណបក្សទៅតាមជំរើសរបស់គេ ដោយគ្មានការបង្ខិតបង្ខំ សំណូកសូកប៉ាន់ ហឹង្សា គំរាមកំហែងឡើយ។
- ដំណើរការបោះឆ្នោតត្រូវតែអនុវត្តអោយមានយុត្តិធម៌ ដែលអាចធ្វើអោយពលរដ្ឋគ្រប់រូបអាចបោះឆ្នោតបាន ។
- ត្រូវមានឱកាសប្រកួតប្រជែងស្មើភាពគ្នា គឺមានន័យថា គណបក្ស ឬ បេក្ខជនទាំងអស់ អាចប្រកួតប្រជែងដោយយុត្តិធម៌សំរាប់អោយអ្នកបោះឆ្នោតគាំទ្រ ។

សុំអ្នករៀនលើកឡើងនូវអ្វីដែលគេយល់ឃើញអំពីពាក្យថា "ការបោះឆ្នោតដោយសេរី និង មានយុត្តិធម៌" ។ យើងត្រូវសរសេរយោបល់របស់គេដាក់លើក្រដាសផ្ទាំង ឬ ក៏លើក្តារខៀន ។

> *គន្លឹះសំខាន់* : សូមមើលផ្នែកទី ៥ ក្នុងឯកសារបន្ថែមចំពោះពត៌មានបន្ថែមទៀត ស្តីអំពីការបោះឆ្នោតដោយសេរី និង យុត្តិធម៌ ។

## II. បង្រៀនអំពី : ហេតុអ្វីចាំបាច់បោះឆ្នោត ?

..... ***នាទី***

សុំអោយរៀនឆ្លើយនឹងសំណួរថា : តើហេតុអ្វីចាំបាច់បោះឆ្នោត ?

កត់ត្រាទុករាល់ចំលើយក្នុងក្រដាសផ្ទាំង ហើយត្រូវគូសបញ្ជាក់នូវអ្វីដែលគេធ្លាប់ស្គាល់ និង អ្វីដែលខុសគ្នា ផ្សេងគ្នា ក្នុងចំលើយរបស់គេ រួចធ្វើសង្ខេបអំពីចំលើយរបស់គេ ។

> *គន្លឹះសំខាន់* : ក្នុងពេលបើកវគ្គបង្រៀនផ្នែកនេះ យើងត្រូវតែចងចាំយោបល់របស់ក្រុមមុខសញ្ញាស្ទង់មតិដែលគេបង្ហាញពីរបៀបដែលពលរដ្ឋកម្ពុជាយល់ឃើញអំពីការបោះឆ្នោត ។ ប្រជាពលរដ្ឋភាគច្រើនមានគំនិតយល់ស្របក្នុងការបោះឆ្នោត ប៉ុន្តែពួកគេមិនមានអារម្មណ៍ថា ការបោះឆ្នោតរបស់គេ ប្រាកដជាកែប្រែការរស់នៅរបស់ពួកគេនោះទេ ។

*យើងត្រូវពន្យល់អ្នករៀនថា :*

ការបោះឆ្នោត គឺជាដំណើរការមួយដែលបុគ្គលមានសិទ្ធិគ្រប់រូបសំដែងពីចំណូលចិត្តរបស់គេទៅលើរឿងនយោបាយ ។

- តាមរយៈការបោះឆ្នោតនេះ ពលរដ្ឋរាល់រូប អាចទទួលកាន់កាប់លើជីវិតរស់នៅរបស់គេ និង មើលការខុសត្រូវលើហេតុការណ៍ដែលនឹងកើតមានឡើងចំពោះសហគមន៍របស់គេ ។
- ការបោះឆ្នោតនេះ ធានាអោយពលរដ្ឋទាំងអស់មានឱកាសបោះឆ្នោតជ្រើសរើសបេក្ខជនដែលចេះចែករំលែកផលប្រយោជន៍ និង សេចក្តីខ្វាយខ្វល់រួមគ្នា ។ ការបោះឆ្នោតនេះ ក៏ផ្តល់ឱកាសអោយពលរដ្ឋដកហូតតំណាងរបស់ខ្លួនដែលមិនពេញចិត្តចេញពីតំណែង (អំណាច) បានដែរ ។
- ការបោះឆ្នោត គឺជាវិធីដ៏មានសន្តិភាពមួយ ដែលកំណត់សំរេចជ្រើសរើសយកអ្នកដែលត្រូវកាន់អំណាចនយោបាយ ។
- ការបោះឆ្នោត គឺជាការបង្ហាញអំពីការប្តេជ្ញារបស់ពលរដ្ឋចំពោះដំណើរការលទ្ធិប្រជាធិបតេយ្យ ហើយនិងបញ្ជូនសញ្ញាទៅអោយអ្នកឯទៀតៗដែលគេយល់ដឹង និង ចង់អនុវត្ត ឬប្រើសិទ្ធិរបស់គេ ។

> *គន្លឹះសំខាន់* : យើងត្រូវជួយរំលឹកដល់អ្នករៀនអោយចងចាំ ឬ នឹកឡើងវិញនូវនិយមន័យរបស់លទ្ធិប្រជាធិបតេយ្យដែលបានពិភាក្សាគ្នារួចមកហើយ ក្នុងជំពូក (ម៉ូឌុល) ទី ២ ។ លទ្ធិប្រជាធិបតេយ្យ គឺជាទំរង់មួយរបស់រដ្ឋាភិបាលដែលប្រជារាស្ត្រអាចជ្រើសរើសអ្នកដឹកនាំរដ្ឋាភិបាលរបស់គេ ហើយអ្នកដឹកនាំទាំងនោះ ទទួលខុសត្រូវចំពោះវិធីដឹកនាំគ្រប់គ្រងប្រទេសជាតិ ។

III. លំហាត់ : គោលការណ៍ជាមូលដ្ឋាននៃការបោះឆ្នោត

..... ***នាទី***

យើងត្រូវយករូបភាពដែលមានមនុស្សកំពុងបោះឆ្នោតបង្ហាញអោយអ្នករៀនមើល រួចត្រូវសុំអោយអ្នករៀនរកមើលខ្លឹមសារផ្សេងៗដែលមានបង្ហាញនៅក្នុងរូបភាព ។ យើងត្រូវជួយអ្នករៀន ដោយសួរគាត់អំពីអ្វីដែលគាត់មើលឃើញ :

- តើមនុស្សក្នុងរូបភាពជាមនុស្សប្រភេទណា ជាអ្នកមាន អ្នកក្រ ជាបុរស ជាស្ត្រី ជាទីក្រុង ឬជាជនបទ ?
- តើអ្នករៀនមានមើលឃើញសន្លឹកឆ្នោតដែលអ្នកបោះឆ្នោតកំពុងតែដាក់ចូលទៅក្នុងហិប (ប្រអប់) ឆ្នោតនោះឬទេ ?
- តើគំនូរក្នុងរូបភាពនោះ មើលទៅមានសន្តិភាពល ឬ ក៏ជារឿងគួរអោយខ្លាច ?

យើងត្រូវលើកយកយោបល់របស់អ្នករៀន មកចង្អុលបង្ហាញអោយឃើញអំពីកត្តាច្បាស់លាស់នានា ដែលមាននៅក្នុងរូបគំនូរ រួចប្រាប់អ្នករៀនថា រូបភាពនេះបង្ហាញអំពីសារៈសំខាន់ចាំបាច់នៃការបោះឆ្នោត ដូចជា :

*តើនរណាខ្លះអាចបោះឆ្នោតបាន ?*

យើងត្រូវពន្យល់ប្រាប់អ្នកមករៀននោះថា រដ្ឋធម្មនុញ្ញរបស់កម្ពុជាក៏បានផ្តល់សិទ្ធិបោះឆ្នោតទៅអោយៈ

- ពលរដ្ឋកម្ពុជា ទាំងបុរស នារី ដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ។
- អ្នកដែលមានលក្ខណៈសម្បត្តិដូចខាងលើនេះហើយដែលបានចុះឈ្មោះបោះឆ្នោត ។

មានតែពលរដ្ឋខ្មែរប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតអោយបោះឆ្នោតនៅក្នុងសម័យបោះឆ្នោតនោះ ។ ច្បាប់សញ្ជាតិរបស់ប្រទេសកម្ពុជា បានរកឃើញវិធីដែលអាចអោយមនុស្សម្នាក់ក្លាយទៅជាពលរដ្ឋពេញសិទ្ធិរបស់ប្រទេស ដូចមានចែងខាងក្រោមនេះ ៖

- ជនដែលកើតនៅក្នុង ឬ នៅក្រៅប្រទេសកម្ពុជា សុទ្ធតែអាចក្លាយទៅជាពលរដ្ឋពេញសិទ្ធិបានទាំងអស់ អោយតែមានម្តាយ ឬ មានឪពុកជាពលរដ្ឋកម្ពុជាពេញសិទ្ធិ ។
- ជនដែលកើតនៅប្រទេសកម្ពុជា ប៉ុន្តែមានឪពុកម្តាយបរទេស ដែលកំពុងរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជា ។
- ជនដែលបានរៀបការជាមួយពលរដ្ឋខ្មែរពេញសិទ្ធិ ហើយរស់នៅជាមួយគ្នាបាន ៣ ឆ្នាំ ។
- ជនបរទេសអាចដាក់ពាក្យសុំចូលសញ្ជាតិខ្មែររស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន ហើយការងារដែលត្រូវបំពេញសំណុំបែបបទសុំចូលសញ្ជាតិនោះ មានចែងយ៉ាងលំអិតនៅក្នុងច្បាប់សញ្ជាតិ។

ចូរធ្វើអោយប្រាកដប្រជាថា អ្នកដែលមករៀនយល់នូវចំណុចនានា ដែលយើងបានបង្រៀនហើយ មុនពេលដែលយើងធ្វើការបន្តទៅគំនិតថ្មីទៀត ។

*តើគោលបំណងនៃការចុះឈ្មោះមានអ្វីខ្លះ ?*

- ការចុះឈ្មោះ គឺជាការងារមួយដែលគេកត់ឈ្មោះមនុស្សគ្រប់រូបដែលមានលក្ខណៈសម្បត្តិ និងសិទ្ធិគ្រប់គ្រាន់នឹងបោះឆ្នោត ។

- ការចុះឈ្មោះនេះ វាជួយធ្វើមិនអោយមនុស្សបោះឆ្នោតលើសពីម្តង ។ ហើយក៏ជួយការពារមិនអោយអ្នកដែលពុំមែនជាពលរដ្ឋខ្មែរពេញសិទ្ធិចូលទៅបោះឆ្នោតបានដែរ ។

| |
|---|
| *គន្លឹះសំខាន់* : យើងត្រូវពន្យល់ថា ច្បាប់បោះឆ្នោតពុំទាន់អនុមត់នៅឡើយ ហើយពត៌មានសំខាន់ៗទាំងនេះស្តីអំពីការចុះឈ្មោះ និង របៀបបោះឆ្នោតក៏ពុំទាន់ដឹងនៅឡើយដែរ ។ ត្រូវប្រាប់អ្នករៀនថា អ្នកនឹងដឹងពត៌មានច្រើនថែមទៀត ក្រោយច្បាប់បោះឆ្នោតបានអនុម័ត ។ |

នៅពេលយើងចុះឈ្មោះបោះឆ្នោត យើងត្រូវអោយកាតចុះឈ្មោះទៅអ្នកចុះឈ្មោះ ។ យើងប្រើប្រាស់កាតនេះសំរាប់ជាភស្តុតាងសំគាល់ឈ្មោះ អ្នកបោះឆ្នោតនៅថ្ងៃបោះឆ្នោត ។

ដោយសារថា ច្បាប់បោះឆ្នោតពុំទាន់អនុម័តនៅឡើយនោះ យើងមិនទាន់អាចប្រាប់អ្នករៀនអោយដឹងថា គេត្រូវចុះឈ្មោះបោះឆ្នោតយ៉ាងណា និង នៅទីណានោះដែរ ។ ដូច្នេះយើងត្រូវប្រាប់គេថា យើងនឹងខិតខំប្រមូលពត៌មាននេះយកមកប្រាប់គេទៀត នៅពេលបានទទួលពត៌មានថែមទៀត ។

## *របៀបបោះឆ្នោត*

ដោយសារថា ច្បាប់បោះឆ្នោតពុំទាន់អនុមត់នៅឡើយនោះ យើងពុំទាន់ដឹងពិតប្រាកដថា របៀបបោះឆ្នោតវាយ៉ាងដូចម្តេច ។ នៅឆ្នាំ ១៩៩៣ សម័យបោះឆ្នោត ដែលត្រួតពិនិត្យដោយអ៊ុនតាក់គឺ ៖

- អ្នកបោះឆ្នោតបានគូសឈ្មោះគណបក្សណាមួយដែលខ្លួនពេញចិត្ត លើក្រដាស់បោះឆ្នោត
- មន្ត្រីបោះឆ្នោតបានលាបសញ្ញាលើម្រាមដៃអ្នកបោះឆ្នោត ដើម្បីសំគាល់ថា មនុស្សនេះបានបោះឆ្នោតរួចហើយ ។ ធ្វើរបៀបនេះ ដើម្បីការពារកុំអោយមនុស្សនេះបោះឆ្នោតពីរដង ។
- ចំពោះអ្នកណាដែលបានបាត់កាតចុះឈ្មោះបោះឆ្នោត ពួកគេអាចបោះឆ្នោតបាន ប៉ុន្តែពួកគេត្រូវបានប្រើប្រាស់សន្លឹកឆ្នោតអនុគ្រោះ ។

អ្នករៀនអាចមានសំណួរថា តើសញ្ញានៅលើសន្លឹកឆ្នោតតំណាងអោយគណបក្ស ឬ ថាតើបេក្ខជនម្នាក់ៗត្រូវការជាតំណាងគណបក្ស ឬ ក៏ជាឯកត្តជន ។ ពត៌មាននេះ ពុំទាន់អាចដឹងបានទេ ព្រោះច្បាប់បោះឆ្នោត ពុំទាន់បានត្រូវអនុម័តនៅឡើយ ។

+ *តើហេតុអ្វីបានជាត្រូវបោះឆ្នោតដោយសំងាត់ ?*

- ការបោះឆ្នោតដោយសំងាត់មានន័យថា មានតែមនុស្សដែលកាន់សន្លឹកឆ្នោតនោះប៉ុណ្ណោះ ដែលដឹងថា ខ្លួនបានបោះឆ្នោតអោយនរណាឬគណបក្សណា នៅទីកន្លែងបោះឆ្នោតនោះ ។ អ្នកបោះឆ្នោតមិនចាំបាច់ត្រូវប្រាប់គេថា យើងបោះអោយនរណា ឬ គណបក្សណានោះឡើយ ទោះជាប៉ូលីស ទាហាន មន្ត្រីរាជការ ឬ ក៏ជាសមាជិកក្នុងគ្រួសារតែមួយក៏ដោយ ។

• គេធ្វើអោយមានការបោះឆ្នោតដោយសំងាត់នេះ គឺចង់អោយអ្នកបោះឆ្នោតមានសិទ្ធិ និង សេរីភាពគ្រប់គ្រាន់ ដើម្បីបោះឆ្នោតអោយគណបក្សដែលខ្លួនពេញចិត្ត ដោយមិនបាច់ភ័យខ្លាចគេបង្ខិតបង្ខំអ្វីឡើយ ។

*តើការសំងាត់នោះត្រូវបានការពារយ៉ាងណាខ្លះ ?*

• គ្មាននរណាអាចមើលឃើញ (ដឹង) បានថា អ្នកកាន់ឆ្នោតគូសយ៉ាងណាទេ នៅលើសន្លឹកនោះ ។
• ជាទូទៅ អ្នកចូលបោះឆ្នោតត្រូវចូលទៅគូសសន្លឹកឆ្នោតខ្លួននៅក្នុងបន្ទប់មួយដែលមានវាំងននបាំង ឬក៏មានរបាំងត្រូវគេរៀបចំដាក់បាំងមិនអោយអ្នកទទួលខុសត្រូវនៅទីបោះឆ្នោត មើលឃើញសកម្មភាពអ្នកបោះឡើយ ។

ត្រូវសាកសួរអ្នករៀនក្រែងគេមានបញ្ហាអ្វីសួរអំពីការបោះឆ្នោតដោយសំងាត់នោះ ព្រោះថា អ្នករៀនអាចមានសំណួរច្រើនអំពីការដែលគេត្រូវពិភាក្សាគ្នាក្នុងក្រុមគ្រួសារគេ អំពីសន្លឹកឆ្នោតដែលគេនឹងបោះនោះ ដូច្នេះ យើងត្រូវពន្យល់គេថា គេអាចជជែកពិភាក្សាគ្នាបាន បើគេចង់សួរគ្នានោះ ប៉ុន្តែគេមិនត្រូវប្រាប់នរណាម្នាក់ថា គេបោះអោយនរណានោះឡើយ ។ មុនពេលឈានទៅបង្រៀនចំណុចមួយទៀត យើងដឹងជាមុនសិនថា អ្នករៀនគ្រប់រូប បានយល់រាល់ចំណុចដែលយើងបានបង្រៀនរួចមកហើយ ។

អ្នកត្រួតពិនិត្យមើលការបោះឆ្នោះ និងតំណាងផ្សេងៗទៀត ក្នុងថ្ងៃបោះឆ្នោតបន្ថែមទៅលើមន្ត្រីទទួលបន្ទុកខាងការបោះឆ្នោត មានវត្តមានមនុស្សជាច្រើនទៀតនៅស្ថានីយបោះឆ្នោត នៅថ្ងៃបោះឆ្នោត ។ មនុស្សទាំងនោះរួមមាន ៖

• អ្នកត្រួតពិនិត្យមើលរបស់គណបក្ស : មនុស្សទាំងនេះជាតំណាងមកពីគណបក្សនយោបាយដើម្បីសង្កេតមើលការបោះឆ្នោតនៅថ្ងៃបោះឆ្នោត ។ មនុស្សទាំងនោះ ទទួលខុសត្រូវរាយការណ៍អំពីបញ្ហា ឬ ភាពមិនប្រក្រតីដែលគេឃើញនៅពេលបោះឆ្នោត អោយទៅមន្ត្រីបោះឆ្នោត ។
• អ្នកសង្កេតការណ៍ក្នុងស្រុកដែលមិនបំរើអោយគណបក្សមនុស្សទាំងនេះ ជាតំណាងមកពីអង្គការក្រៅរដ្ឋាភិបាលកម្ពុជា ដូចជាអង្គការសិទ្ធិមនុស្ស ។ ពួកគេមានតួនាទីរាយការណ៍អំពីអ្វីដែលគេបានឃើញ ទៅអោយអង្គការរបស់គេ ។ ជួនកាលពួកគេក៏រាយការណ៍ទៅអោយមន្ត្រីបោះឆ្នោតផងដែរ ។ អ្នកសង្កេតការណ៍ក្នុងស្រុកទាំងនោះ ជាប្រជាពលរដ្ឋធម្មតាដែលគេបានហ្វឹកហាត់ជាពិសេសមួយសំរាប់សង្កេតការណ៍ការបោះឆ្នោត ។ ពួកគេជាមនុស្សអព្យាក្រិតហើយមិនអនុគ្រោះដល់គណបក្ស ឬ បេក្ខជនណាមួយឡើយ ។
• អ្នកសង្កេតការណ៍អន្តរជាតិ : គឺជាក្រុមសង្កេការណ៍មកពីប្រទេសផ្សេងៗ អ្នកសង្កេតការណ៍ទាំងនោះត្រូវតែអព្យាក្រិត ហើយត្រូវបានអញ្ជើញមកសង្កេតការណ៍ការបោះឆ្នោតដោយរដ្ឋាភិបាល

កម្ពុជា ។ ពួកគេមានតួនាទីធ្វើសេចក្តីថ្លែងការណ៍មួយ ឬ របាយការណ៍មួយស្តីអំពីការបោះឆ្នោតបន្ទាប់ពីការបោះឆ្នោតត្រូវបានបញ្ចប់ ។

អ្នកសង្កេតការណ៍ទាំងអស់នេះ ជួយធានាអោយការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី និងយុត្តិធម៌ ។ បើសិនអ្នកឃើញមានបញ្ហាកើតមានឡើងនៅថ្ងៃបោះឆ្នោត ឬ មុនថ្ងៃបោះឆ្នោត អ្នកត្រូវតែផ្តល់ពត៌មានទៅអោយអង្គការត្រួតពិនិត្យក្នុងស្រុក ដូចជា រួមការងារជាមួយអ្នក ។ អ្នកសារពត៌មានក៏មានវត្តមាននៅថ្ងៃបោះឆ្នោតនោះដែរ ។ ពួកគេនៅទីនោះ ដើម្បីសង្កេតការណ៍ និង រាយការណ៍អំពីសកម្មភាពថ្ងៃបោះឆ្នោត ។

## IV. ពត៌មានបង្រៀនអំពី : តើអ្នកបោះឆ្នោតមានសិទ្ធិអ្វីខ្លះ ?

..... ***នាទី***

យើងត្រូវប្រាប់អ្នករៀនថា ពួកគាត់ម្នាក់ៗ មានសិទ្ធិជាអ្នកបោះឆ្នោត ។ លទ្ធិប្រជាធិបតេយ្យភាគច្រើនតែងតែផ្តល់សិទ្ធិដូចតទៅនេះ ដល់ពលរដ្ឋពេញសិទ្ធិរបស់គេ ៖

- អ្នកបោះឆ្នោតមានសិទ្ធិបោះឆ្នោតដោយសំងាត់
- អ្នកបោះឆ្នោតមានសិទ្ធិបោះឆ្នោតអោយគណបក្សដែលខ្លួនពេញចិត្ត ដោយមិនមានសេចក្តីភ័យខ្លាច ឬ ក៏មានអំពើហឹង្សាណាមួយកើតឡើងមកលើខ្លួន ។
- អ្នកបោះឆ្នោតមានសិទ្ធិចូលរួមបោះឆ្នោតទៀងទាត់ដែលមានលក្ខណៈសេរី និង យុត្តិធម៌ ។
- អ្នកបោះឆ្នោតមានសិទ្ធិបោះបានតែម្តងប៉ុណ្ណោះ ក្នុងអាណត្តិបោះឆ្នោតម្តងៗ ។
- អ្នកបោះឆ្នោតត្រូវមានសិទ្ធិ និង មានលទ្ធភាពបានដឹងពីរាល់ទស្សនៈ និង ស្ថានភាពរបស់គណបក្សទាំងអស់ ដើម្បីអោយគេអាចជ្រើសរើសអ្នកដែលគេពេញចិត្តសំរាប់បោះអោយ ។ ប្រពន្ធ័ផ្សព្វផ្សាយពត៌មាន ដូចជាវិទ្យុ សារពត៌មាន ទូរទស្សន៍ និង ទស្សនាវដ្តីជាដើមនោះត្រូវតែផ្តល់ពេលវេលាស្មើគ្នាៗ គ្រប់គណបក្សទាំងអស់សំរាប់អោយគេផ្សព្វផ្សាយ និង ឃោសនាអំពីគណបក្សរបស់គេថា គេមានគោលជំហរបែបណាខ្លះ ?

| |
|---|
| ការបោះឆ្នោតកាលពីឆ្នាំ ១៩៩៣ ដែលបានធ្វើឡើងដោយអ៊ុនតាក់ : ពីថ្ងៃទី ២៣ ដល់ ២៥ ខែ ឧសភា ឆ្នាំ ១៩៩៣ ប្រទេសកម្ពុជាបានធ្វើការបោះឆ្នោតតាមលទ្ធិប្រជាធិបតេយ្យ ដំបូងបង្អស់របស់ខ្លួន ។ ប្រជាពលរដ្ឋខ្មែរបានបោះឆ្នោតជ្រើសរើសមនុស្ស ១២០ រូប អោយតំណាងខ្លួននៅក្នុងសភាធម្មនុញ្ញ (ដែលក្លាយទៅជាសភាជាតិ បន្ទាប់ពីរដ្ឋធម្មនុញ្ញត្រូវបានអនុម័ត ។ កាលពីជំនាន់អ៊ុនតាក់បោះឆ្នោតមានមនុស្សចំនួនជាង ៤.៧ លាននាក់ បានចុះឈ្មោះបោះឆ្នោត ។ ហើយប្រជាជនចំនួននេះ ប្រមាណជា ៩០% បានប្រើសិទ្ធិខ្លួនទៅបោះឆ្នោត ។ |

*ជាសំខាន់យើងត្រូវលើកចំណុចខាងក្រោមនេះមកបញ្ជាក់ ៖*

- មនុស្សគ្រប់ៗរូបមានសិទ្ធិបោះឆ្នោត
- សន្លឹកឆ្នោតមួយៗជាសន្លឹកឆ្នោតសំងាត់

- គ្មាននរណាប្រាប់អ្នកណាថា ត្រូវបោះឆ្នោតអោយនរណានោះទេ ។ យើងអាចបោះអោយនរណាក៏បានដែរ អោយតែយើងពេញចិត្ត ។

*កាលពីឆ្នាំ ១៩៩៣ មានបញ្ហា (រំលោភបំពាន) ខ្លះៗ បានកើតឡើងដូចជា ៖*

- មានអ្នកបោះឆ្នោតខ្លះត្រូវបានគេដកហូតបណ្ណសមាជិកគណបក្សរបស់ខ្លួន ។ ផ្ទុយទៅវិញ មានគេអោយបណ្ណសមាជិកគណបក្សទៅអ្នកនោះដោយខ្លួនមិនចង់ចូលជាសមាជិក ។ សូមចាំថា : ទោះជាមានគេដកហូតបណ្ណសមាជិកគណបក្សរបស់អ្នកដែលជាសមាជិករបស់គណបក្ស "X" ក៏ដោយ ក៏អ្នកនៅតែអាចបោះឆ្នោតអោយគណបក្ស "X" នោះវិញបានដែរ ហើយបើអ្នកមានបណ្ណសមាជិកគណបក្ស "Y" វិញនោះ ក៏អ្នកមិនមែនត្រូវតែបោះឆ្នោះអោយគណបក្ស "Y" នោះដែរ ។
- មានមនុស្សខ្លះបានត្រូវបង្ខិតបង្ខំ ឬ គំរាមកំហែងដោយអំពើហឹង្សា ដោយសារតែខ្លួនគាំទ្រដល់គណបក្សណាមួយ ដូច្នេះសូមចាំថា : បើមាននរណាម្នាក់មកគំរាមកំហែងអ្នក ហើយប្រាប់អ្នកថាអោយបោះឆ្នោតគាំទ្រគណបក្ស "X" នោះ អ្នកក៏មិនត្រូវតែបោះឆ្នោតអោយគណបក្សនោះដែរ ទោះជាអ្នកបានប្រាប់គេថា អ្នកនឹងបោះអោយនោះក៏ដោយ ពីព្រោះថា សន្លឹកឆ្នោតដែលអ្នកបោះ គឺជាសន្លឹកឆ្នោតសំងាត់ ហើយអ្នកអាចបោះអោយនរណា គណបក្សណា ក៏បានដែរ អោយតែអ្នកពេញចិត្ត ។ បើមានគេគំរាមកំហែងអ្នក អ្នកត្រូវរកវិធីរាយការណ៍អោយក្រុមសិទ្ធិមនុស្សដែលត្រួតពិនិត្យមើលការបោះឆ្នោត ។

យើងត្រូវឆ្លើយប្រាប់អ្នករៀនវិញ បើគេមានសំណួរអំពីសិទ្ធិរបស់គេ ក្នុងនាមជាអ្នកបោះឆ្នោតនោះ ។ យើងក៏ត្រូវឆ្លៀតយកឱកាសនេះលើកយកមកជជែកគ្នាអំពីឧទាហរណ៍ខ្លះ ដែលយើង ឬ ក៏អ្នករៀនដឹងអំពីការល្មើសលើសិទ្ធិមនុស្សដូចដែលយើងបានពន្យល់រួចមកនោះ ។ មុនពេលឆ្លងទៅបង្រៀនអំពីចំណុចផ្សេងទៀត យើងត្រូវតែដឹងជាមុនសិនថា អ្នករៀនបានយល់អស់ពីអ្វីដែលយើងបានបង្រៀនរួមកនោះ ។

## V. លំហាត់ : តើយើងត្រូវធ្វើយ៉ាងម៉េចដើម្បីអោយមានការបោះឆ្នោតសេរី និង មានយុត្តិធម៌

….. ***នាទី***

សុំអោយអ្នករៀនចូលគ្នាបង្កើតជាក្រុមតូចៗ ដែលមានមនុស្ស ៣ ឬ ៤ នាក់ ក្នុងមួយក្រុមៗ រួចសុំអោយគាត់ធ្វើការពិភាក្សាគ្នាលើសំណួរថា : តើយើងត្រូវធ្វើយ៉ាងណាដើម្បីអោយមានការបោះឆ្នោតសេរី និងមានយុត្តិធម៌ ? នេះ ។ ក្រុមនីមួយៗ ត្រូវត្រៀមខ្លួនបង្ហាញដល់ក្រុមធំ (ទាំងមូល) នូវអ្វីដែលក្រុមខ្លួននីមួយៗ បានយល់ឃើញថា ត្រូវធ្វើយ៉ាងណាៗនោះ ។

យើងត្រូវហៅក្រុមពិភាក្សាមួយៗមករាយការណ៍ដល់ក្រុមធំ រួចយើងត្រូវកត់ទុកយោបល់របស់ក្រុមនីមួយៗនៅលើក្រដាសផ្ទាំង ។ យើងត្រូវឃាត់អ្នករៀនកុំទាន់អោយជជែកគ្នា លុះត្រាណាតែគ្រប់ៗក្រុមអាច

មានឱកាសនឹងរាយការណ៍សិន សឹមលើកអោយពិភាក្សា ។ កាលណាគ្រប់ៗក្រុម បានរាយការណ៍រួចរាល់ហើយ យើងត្រូវសុំអោយក្រុមទាំងមូល (ក្រុមធំ) អោយយោបល់លើគំនិតរបស់ក្រុមទាំងអស់ ។ យើងអាចអោយយោបល់ខ្លះៗដូចតទៅ ៖

១. ស្ម័គ្រចិត្តជួយគ្រប់គ្រងទីបោះឆ្នោត
២. ស្ម័គ្រចិត្តធ្វើជាអ្នកសង្កេតការណ៍ប្រចាំភូមិ ស្រុក របស់ខ្លួន
៣. ត្រូវរាយការណ៍អំពីអ្វីដែលខុសឆ្គង ដូចជា បើមានអំពើឃោរឃៅណាមួយ ការបង្ខិតបង្ខំណាមួយ ក្រែងមានបញ្ហាពាក់ព័ន្ធនឹងហិបឆ្នោត មានការស្នូកចាន់ អោយបានដឹងដល់ក្រុមក្រុមសង្កេតការណ៍ អង្គការសិទ្ធិមនុស្ស ប៉ូលីស ឬ អាជ្ញាធររដ្ឋ ។
៤. ត្រូវជួយដាស់តឿនក្រុមគ្រួសារខ្លួន និង អ្នកជិតខាងរបស់ខ្លួនអោយទៅចុះឈ្មោះ និង បោះឆ្នោត ។
៥. ត្រូវជួយដល់អ្នកដទៃ ដើម្បីអោយគេអាចបោះឆ្នោតបាន ។

ត្រូវធ្វើការសន្និដ្ឋានលើការពិភាក្សាកន្លងមក ដោយជំរុញអោយអ្នករៀនធ្វើអ្វីមួយដែលគេអាចធ្វើបានដើម្បីអោយមានការបោះឆ្នោតមួយសេរី និង មានយុត្តិធម៌ ។

★ <u>សេចក្តីសន្និដ្ឋាន</u>

...... ***ខាទី***

ធ្វើសេចក្តីសន្និដ្ឋានអំពីការរៀនសូត្រកន្លងមក ដោយជួយជំរុញលើកទឹកចិត្តអ្នករៀនគ្រប់ៗរូបអោយទៅចុះឈ្មោះ និង បោះឆ្នោះនៅឱកាសបោះឆ្នោតថ្ងៃខាងមុខនេះ ។

ត្រូវជួយរំលឹកគេថា នេះគឺសិទ្ធិរបស់គេ ហើយក៏ជាភារកិច្ចទទួលខុសត្រូវរបស់គេដែរ ដែលគេត្រូវតែបោះឆ្នោតសេរី និង មានយុត្តិធម៌ ។

***<u>ការវាយតំលៃ</u>***

វាមានសារៈសំខាន់ណាស់ដែលត្រូវអោយមានការវាយតំលៃលើវគ្គរៀនសូត្រនោះ ។ យើងត្រូវការដឹងថា អ្នកដែលយើងបង្រៀននោះ បានយល់ដឹងច្បាស់អំពីខ្លឹមសារដែលយើងបានបង្រៀនគេ ។ ការដែលយើងអោយអ្នករៀនវាយតំលៃវគ្គរៀនសូត្រនេះ យើងប្រាកដជាអាចកែលំអការបង្រៀនរបស់យើងលើកក្រោយៗអោយលប្រសើរជាងនេះទៀត ។

បែបបទសំរាប់បំពេញវាយតំលៃវគ្គរៀនសូត្រនេះ មានភ្ជាប់នៅទំព័របន្ទាប់នេះ ។ យើងត្រូវរៀបចំបែបបទនេះសំរាប់ចែកអោយអ្នករៀនម្នាក់ៗគ្រប់ៗរូបសំរាប់ធ្វើការវាយតំលៃ ។ បើអ្នករៀនណាម្នាក់មិនចេះអក្សរ យើងត្រូវអានសំណួរនីមួយៗ និង ចំលើយសំរាប់អោយគាត់ជ្រើសរើសឆ្លើយនោះ អោយបានឮច្បាស់ៗអោយគាត់ស្តាប់ ។ យើងត្រូវតែចងចាំការវាយតំលៃអោយបានជាប់ជានិច្ច ។

## ***<u>វគ្គបង្រៀនអំពីការអប់រំពលរដ្ឋ និង អ្នកបោះឆ្នោត</u>***

សូមអោយអ្នករៀនមេត្តាបំពេញបែបបទនេះ រួចជូនទៅអ្នកបង្រៀនវិញ ហើយយើងត្រូវថ្លែងអំណរគុណដល់គេដែលបានឆ្លើយតបមកយើងវិញនោះ ។

*<u>សំណួរទី ១</u>*

សូមមេត្តាអោយពិន្ទុទៅលើគុណភាពនៃវគ្គរៀនសូត្រនេះ

លមែនទែន ................... ល .................. មធ្យម ............

មិនលសោះ ....................

*<u>សំណួរទី ២</u>*

តើពត៌មានដែលយើងបានបង្រៀនអ្នកនោះ មានប្រយោជន៍យ៉ាងណាដែរចំពោះអ្នក ?

មានប្រយោជន៍ណាស់ ........................... មានប្រយោជន៍ .....................

មិនមានប្រយោជន៍ប៉ុន្មានទេ ..........................

*<u>សំណួរទី ៣</u>*

តើមេរៀនមួយណា ឬ ប្រធានបទមួយណាដែលអ្នលយល់ថា មានប្រយោជន៍ច្រើនជាងគេ សំរាប់អ្នក ? (ចូរគូសយកចំលើយមួយ) ការរៀបរាប់រូបភាពអំពីលទ្ធិប្រជាធិបតេយ្យ តើអ្វីទៅជាលទ្ធិប្រជាធិបតេយ្យ ? លក្ខណៈនៃលទ្ធិប្រជាធិបតេយ្យ *អត្ថប្រយោជន៍នៃលទ្ធិប្រជាធិបតេយ្យ* លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា តើការបោះឆ្នោតជាអ្វី ? តើហេតុអ្វីចាំបាច់ត្រូវបោះឆ្នោត ? គោលការណ៍មូលដ្ឋាននៃការបោះឆ្នោត តើអ្នកបោះឆ្នោតមានសិទ្ធិអ្វីខ្លះ ? តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីអោយ ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី និង យុត្តិធម៌ ?

*<u>សំណួរទី ៤</u>*

តើពត៌មានអ្វីខ្លះដែលអ្នកចង់ដឹង តែយើងមិនបានបង្រៀន ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

*<u>សំណួរទី ៥</u>*

តើយើងបង្រៀនបានច្បាស់លាស់ ឬ ទេ (សូមគូសយកចំលើយមួយ ) ដោយប្រើពាក្យថា :

ច្បាស់ ☐ មិនច្បាស់ ☐

តើអ្នកបង្រៀនមានការចេះដឹងឬអត់ ? (សូមគូសយកចំលើយមួយ)

មាន ☐ អត់មាន ☐

សូមមេត្តាអោយពិន្ទុគុណភាពរបស់អ្នកបង្រៀន :

ល្អណាស់ ☐ ល្អគួរសម ☐ ល្មមធ្យម ☐ មិនល្អ ☐

*សំណួរទី ៦*

តើអ្នកនឹងយករឿងរៀននេះទៅប្រាប់ដល់អ្នកដទៃឬទេ ?

នឹងប្រាប់ ☐ អត់ប្រាប់ ☐

ហេតុអ្វី ? ........................................................................................................

*សំណួរទី ៧*

ពេលរៀនរួចមកនេះ តើអ្នកយល់ថា អ្នកបានយល់ដឹងជាងមុនច្រើន ហើយត្រៀមខ្លួនថានឹងទៅបោះឆ្នោតជ្រើសរើសមេឃុំ និង ជ្រើសរើសអ្នកដឹកនាំប្រទេសជាតិឬទេ ?

បានត្រៀមខ្លួននឹងបោះឆ្នោត ☐ មិនគិតថាទៅបោះឆ្នោតទេ ☐

# ឯកសារបន្ថែម
# នៃសៀវភៅសំរាប់អ្នកហ្វឹកហ្វឺន
# ការអប់រំ
# ពលរដ្ឋ និង អ្នកបោះឆ្នោត

## I. គោលបំណងនៃឯកសារបន្ថែមនេះ

ឯកសារបន្ថែមនេះ វាជួយអមខ្លឹមសារសៀវភៅសំរាប់អ្នកមាននាទីអប់រំរំលែលពលរដ្ឋ និង អ្នកបោះឆ្នោត ។ ឯកសារនេះវាមានខ្លឹមសារពត៌មានដែលអាចជួយអ្នកអោយពន្យល់ដល់អ្នករៀនអំពីសារៈសំខាន់នៃការបោះឆ្នោតនៅក្នុងប្រទេសមួយ ដែលប្រកាន់តាមលទ្ធិប្រជាធិបតេយ្យ ហើយឯកសារនេះ ក៏ផ្តល់ពត៌មានលំអិតបន្ថែមអំពីគំនិតសំខាន់ៗផងដែរ ដូចជា អំពីលទ្ធិប្រជាធិបតេយ្យ និង ការបោះឆ្នោតជាដើម ដែលបានយកមកប្រើប្រាស់នៅក្នុងសៀវភៅនេះ ។

យើងត្រូវតែមើលឯកសារនេះសារឡើងវិញ មុនពេលចេញទៅបង្រៀនដើម្បីអោយយើងអាចត្រៀមលក្ខណៈនិយាយអំពីវគ្គផ្សេងៗគ្នារបស់សៀវភៅនេះ នៅពេលដែលយើងត្រូវការអ្វីមួយនោះ ។ ឧទាហរណ៍ថា បើមានអ្នករៀនណាម្នាក់មានការពិបាកយល់ពាក្យពេចន៍ ឬ ក៏គោលគំនិតណាមួយនោះ យើងអាចលើកយកឧទាហរណ៍នានាពីសៀវភៅនេះ ទៅបង្ហាញគាត់អំពីចំណុចដែលគាត់មិនយល់នោះ ។ ឯកសារបន្ថែមនេះ ក៏អាចយកទៅប្រើប្រាស់ក្នុងពេលដែលអ្នករៀនគេសួរយើងមកនោះ ។

## II. ប្រវត្តិបោះឆ្នោតនៅកម្ពុជា

នៅកម្ពុជា មានការបោះឆ្នោតចំនួនប្រាំលើកមកហើយ ដើម្បីជ្រើសរើសសមាជិកនីតិបញ្ញត្តិជាតិរបស់ប្រទេស (ឥឡូវនេះគេអោយឈ្មោះហៅថា សភា) ។ ការបោះឆ្នោតទាំងប្រាំលើកនោះ មាននៅឆ្នាំ ១៩៤៦, ១៩៤៧, ១៩៥៥, ១៩៧២ និង ១៩៩៣ ។ ក្នុងឱកាសបោះឆ្នោតនានាមុនការបោះឆ្នោតឆ្នាំ ១៩៩៣ នោះ អ្នកបោះឆ្នោត និង បេក្ខជនឈរឈ្មោះ តែងតែត្រូវបានគេបង្ខិតបង្ខំ ហើយគណបក្សនយោបាយដែលជាគណបក្សជំទាស់ជាមួយរដ្ឋាភិបាលជំនាន់នោះ ច្រើនតែមិនសូវបានគេអនុញ្ញាតអោយប្រកួតប្រជែងទៅតាមយុត្តិធម៌ឡើយ ។ មានតែការបោះឆ្នោតនៅឆ្នាំ ១៩៩៣ ប៉ុណ្ណោះ ដែលជាការបោះឆ្នោតលើកទីមួយនៅក្នុងប្រវត្តិសាស្ត្រ ត្រូវគេចាត់ទុកថា ជាការបោះឆ្នោតមានលក្ខណៈ "សេរី និង មានយុត្តិធម៌" ។

កាលពីឆ្នាំ ១៩៥៦ មានច្បាប់មួយបានត្រូវបង្កើត និង អនុម័តយកមកប្រើប្រាស់សំរាប់ធ្វើការបោះឆ្នោតតាមមូលដ្ឋាន និង តាមខេត្ត ។ ច្បាប់នោះចែងអោយមានការបោះឆ្នោតជ្រើសរើសអភិបាលខេត្ត និង ជ្រើសរើសមន្ត្រីនៅថ្នាក់ឃុំ ។

ការបោះឆ្នោតឆ្នាំ ១៩៩៣ បានត្រូវរៀបចំធ្វើដោយអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិសំរាប់កម្ពុជា "អ៊ុនតាក់" ។ អ៊ុនតាក់បានត្រូវបង្កើតឡើងដែលជាផ្នែកមួយនៃកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសក្នុងឆ្នាំ ១៩៩១ និងកិច្ចព្រមព្រៀងដំណោះស្រាយដ៏ធំទូលាយមួយសំរាប់កម្ពុជា ។ កិច្ចព្រមព្រៀងនោះ បានជាលទ្ធផលមក គឺការបញ្ចប់សង្គ្រាមដែលមានរយៈពេលជាង ២០ ឆ្នាំ ហើយនិងការបង្កើតអោយមានរដ្ឋាភិបាលប្រជាធិបតេយ្យមួយឡើង ។ អង្គការសហប្រជាជាតិ បានបង្កើតច្បាប់ និង ទំរង់ការនានាដែលត្រូវបានយកមកប្រើប្រាស់ក្នុងការបោះឆ្នោះឆ្នាំ ១៩៩៣ ។ ទឹកប្រាក់ប្រមាណជាជិត ១.៧០០រយលានដុល្លារអាមេរិក បានត្រូវចំណាយលើការបោះឆ្នោតនោះ ដោយប្រាថ្នាថានាធ្វើអោយការបោះឆ្នោតនោះ វាសន្តិភាព

គ្រប់គ្រាន់ ។ ដើម្បីដំណើរការការបោះឆ្នោតនៅឆ្នាំនោះ អង្គការសហប្រជាជាតិ បានដាក់បុគ្គលិកស៊ីវិលចំនួន ១.៥០០ នាក់ បុគ្គលិកយោធាចំនួន ១៦.០០០ នាក់ និង ភ្នាក់ងារប៉ូលីសចំនួន ៣៦០០ នាក់ ។ លើសពីនេះទៀត នៅមានបុគ្គលិកជាតិកម្ពុជា ចំនួនជាង ៥០.០០០ នាក់ទៀត ដែលបានជួយអង្គការសហប្រជាជាតិ អោយធ្វើការរៀបចំបោះឆ្នោះនោះ ។

ក្នុងការបោះឆ្នោតឆ្នាំ ១៩៩៣ នោះ មានអ្នកបោះឆ្នោតប្រមាណជា ៩០% នៃអ្នកដែលបានចុះឈ្មោះបោះឆ្នោត បានមកចូលរួមបោះឆ្នោតនោះ ។ ក្នុងនោះមានគណបក្សនយោបាយចំនួន ២០ គណបក្ស បានចូលប្រកួតប្រជែង យកកៅអីនៅក្នុងរដ្ឋសភាជាតិ ។ ការបោះឆ្នោតនោះ បានប្រព្រឹត្តទៅដោយយកខេត្តជាមូលដ្ឋានតាមប្រពន្ធ័សមាមាត្រ និង បញ្ជីគណបក្ស (ឧទាហរណ៍ថា : បើគណបក្សមួយបានទទួលសន្លឹកឆ្នោតគាំទ្រ ១០% នៅក្នុងខេត្តគណបក្សនោះក៏បានទទួល ១០% នៃអាសនៈពីខេត្តនោះដែរ) ។ កាលដែលការបោះឆ្នោតបានចប់សព្វគ្រប់ទៅនោះ ពេលនោះមានគណបក្សបួនបានចែកកៅអីទាំង ១២០ កន្លែងដែលមាននៅក្នុងរដ្ឋសភា ដោយគណបក្សហ្វ៊ុនស៊ីនប៉ិច បានឈ្នះកៅអីចំនួន ៥៨ គណបក្សប្រជាជនកម្ពុជា បានទទួល ៥១ កៅអី គណបក្សប្រជាធិបតេយ្យសេរីនិយម ព្រះពុទ្ធសាសនា បានទទួល ១០ កៅអី និងគណបក្សម៉ូលីណាកាបានទទួល ១ កៅអី ។

III. លទ្ធិប្រជាធិបតេយ្យ និង ពហុភាព (សូមមើលផ្នែកទី ២ ក្នុងសៀវភៅសំរាប់បណ្តុះបណ្តាល)

មាត្រា ១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា :

ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រកម្ពុជា ដែលព្រះមហាក្សត្រមួយព្រះអង្គ ដែលទ្រង់នឹងគ្រប់គ្រងប្រទេសទៅតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី និងពហុភាព (មានបញ្ជាក់ជូនបន្ថែមទៀត) ។

### *ក. លទ្ធិប្រជាធិបតេយ្យ*

"លទ្ធិប្រជាធិបតេយ្យ" គឺជាក្រិច ដែលកើតមកពីពាក្យថា "ដេម៉ូស៍" ស្មើនឹងពាក្យថា "ប្រជា" និង ពាក្យថា "ក្រាតូស៍" ដែលមានន័យថា "គ្រប់គ្រង" ។ ដូច្នេះពាក្យថា "ប្រជាធិបតេយ្យ" គឺ វាមានន័យថា "ប្រជា ឬ ប្រជាជន ជាអ្នកគ្រប់គ្រង" ។

នៅក្នុងលទ្ធិប្រជាធិបតេយ្យ ពលរដ្ឋជាអ្នកបោះឆ្នោតជ្រើសរើសមេដឹកនាំរដ្ឋាភិបាលរបស់គេ ដូច្នេះនយោបាយរដ្ឋាភិបាល ត្រូវតែឆ្លុះបញ្ចាំងពីជំនឿ តំលៃថ្លៃថ្នូរ និង បំណងប្រាថ្នារបស់ពលរដ្ឋចំនួនច្រើន ហើយពលរដ្ឋទាំងអស់ ត្រូវមានលទ្ធភាពចូលរួមសំរេចការងារដឹកនាំរបស់រដ្ឋ ដែលវាប៉ះពាល់ដល់ជីវភាពរស់នៅរបស់ខ្លួន ។

នៅប្រទេសក្រិចសម័យដើម លទ្ធិប្រជាធិបតេយ្យបានត្រូវគេអនុវត្តមនៅក្នុងរដ្ឋ រដ្ឋធានីតូចៗ ដូចជា រដ្ឋអាថែនស៍ជាដើម ។ ដោយសារតែរដ្ឋ រដ្ឋធានីទាំងនោះមានទំហំតូចៗស្រាប់នោះ នៅទីនោះពលរដ្ឋអាចធ្វើការជួបជុំគ្នានៅកន្លែងជួបជុំមួយ ហើយធ្វើការសំរេចចិត្តទាំងអស់គ្នា រកវិធីដែលខ្លួនគេត្រូវបានដឹលនាំគ្រប់

គ្រង ។ ឥឡូវនេះ មានប្រទេសជាច្រើនដែលមានទំហំធំៗ ហើយពិបាកនឹងធ្វើការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យនេះដោយផ្ទាល់បាន ។ ដូច្នេះ គេក៏បង្កើតអោយដំណើរការ ឬ របៀប និង ស្ថាប័នថ្មីៗ ដើម្បីអនុញ្ញាតអោយពលរដ្ឋចូលរួមជាមួយរដ្ឋាភិបាលរបស់ខ្លួន ជាឧទាហរណ៍ដូចជា ៖ ជាជាងអោយពលរដ្ឋទាំងអស់មកជួបជុំគ្នា ស្រុះគ្នាតែម្តង ដើម្បីចូលរួមសំរេចការងារផ្សេងៗនោះ ឥឡូវនេះយើងត្រូវជ្រើសរើសតំណាងរបស់យើងអោយគេដើរតួអនុវត្តបំណងប្រាថ្នារបស់យើង គឺរបៀបនេះហើយដែលពលរដ្ឋកម្ពុជាបានធ្វើកាលពីឆ្នាំ ១៩៩៣ ដែលកាលនោះ យើងបានបោះឆ្នោតជ្រើសរើសតំណាងរបស់យើង សំរាប់សភាធម្មនុញ្ញ (ដែលតំណាងរាស្ត្រទាំងអស់នោះ បានក្លាយមកជាសមាជិករដ្ឋសភា បន្ទាប់ពីអនុម័តច្បាប់រដ្ឋធម្មនុញ្ញកាលពីថ្ងៃទី ២១ កញ្ញា ១៩៩៣) នោះមក ។ ទន្ទឹមនោះយើងក៏បានបង្កើតអង្គការនានាផងដែរ សំរាប់អោយជួយយើងទៅប្រាប់មន្ត្រីរដ្ឋាភិបាលថា យើងត្រូវការចង់បានអ្វីនោះ ។ វត្តមានរបស់អង្គការទាំងនេះ ដែលជាអ្នកធ្វើជាសំលេងរបស់យើង និង តំណាងផលប្រយោជន៍របស់យើងនោះ គេអោយឈ្មោះហៅថា "ពហុភាព" ។

## ខ. *ពហុភាព*

ពហុភាពមានន័យថា អង្គការជាច្រើនអាចកើតមានឡើង ហើយនិងធ្វើការងារដោយឯករាជ្យម្ចាស់ការនូវការកាន់កាប់របស់រដ្ឋាភិបាល ។ ពលរដ្ឋគ្រប់រូប អាចបង្កើតអោយមានអង្គការនានាដែលធ្វើអោយពួកគេរួបរួមគ្នាជាមួយអ្នកដទៃ ដែលមានផលប្រយោជន៍ ឬ គោលដៅដូចៗគ្នា ។ ការធ្វើរួមគ្នាតាមអង្គការទាំងនេះ ពលរដ្ឋអាចមានតំណាចច្រើនជាងធ្វើតែម្នាក់ៗឯង ។

អង្គការទាំងនេះ (ជាឧទាហរណ៍) អាចបង្កើតឡើងដោយផ្អែកលើសមាជិកភាពគ្រួសារ ឬ ក៏ជាសាសនាអ្វីមួយ ហើយក៏អាចមានជាគណបក្សនយោបាយ សហជីពពាណិជ្ជកម្ម ក៏ដូចជាក្រុមដែលតំណាងអោយគ្រូបង្រៀន កសិករ និង ក្រុមហ៊ុនពាណិជ្ជកម្មផងដែរ ។ អង្គការទាំងនេះ មានតួនាទីដ៏ធំមួយក្នុងបណ្តាប្រទេសជាតិ ដែលប្រកាន់លទ្ធិប្រជាធិបតេយ្យទំនើប ។

## គ. *លទ្ធិប្រជាធិបតេយ្យ និង រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា*

រដ្ឋធម្មនុញ្ញរបស់កម្ពុជាចែងអោយមាន "លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស" ។ មាត្រា ៥១ នៃច្បាប់រដ្ឋធម្មនុញ្ញបានបញ្ជាក់អំពីការគ្រប់គ្រងរបស់ប្រជារាស្ត្រ ដោយចែងថា "ពលរដ្ឋកម្ពុជា ជាម្ចាស់ជោគវាសនាផ្ទាល់របស់ខ្លួន ហើយនិងថា អំណាចទាំងអស់ជារបស់ពលរដ្ឋ ... " ។ តទៅនេះ គឺ ជា ខចែងច្បាប់រដ្ឋធម្មនុញ្ញសំខាន់ៗមួយចំនួន ដែលជួយធានាអោយរដ្ឋាភិបាលប្រកាន់លទ្ធិប្រជាធិបតេយ្យមួយ ៖

*អធិបតេយ្យភាព*

... ច្បាប់រដ្ឋធម្មនុញ្ញចែងថា "ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រ ដែលព្រះមហាក្សត្រ ទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ហើយនិងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។ ព្រះរាជាណាចក្រកម្ពុជាគឺជារដ្ឋដែលមានឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រិត្យអចិន្ត្រៃយ៍ និង មិនចូលបក្សសម្ព័ន្ធ" (មាត្រា ១) ។

*ព្រះមហាក្សត្រ*

... ក្រោមច្បាប់រដ្ឋធម្មនុញ្ញ "ព្រះមហាក្សត្រទ្រង់គ្រប់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចទេ" (មាត្រា៧) ។

... ព្រះមហាក្សត្រ ត្រូវជ្រើសតាំងដោយក្រុមប្រឹក្សាព្រះរាជសម្បត្តិ ដែលមានសមាសភាព : ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សម្តេចព្រះសង្ឃរាជគណៈមហានិកាយ និង គណៈធម្មយុត្តិ និង អនុប្រធានទី ១ ទី ២ នៃរដ្ឋសភា (មាត្រា ១៣) ។

... ព្រះមហាក្សត្រ គឺជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ ដែលបញ្ជាដោយអគ្គមេបញ្ជាការមួយរូប ។ អំណាចរបស់ព្រះមហាក្សត្រ រួមមាន : សិទ្ធិបន្ធូរទោស និង ផ្តល់ការលើកលែងទោស ហើយព្រះអង្គក៏មានសិទ្ធិ "ឡាយព្រះហស្តលេខាលើសេចក្តីសំរេចព្រះមហាក្សត្រ ដើម្បីដាក់អោយប្រើប្រាស់រដ្ឋធម្មនុញ្ញ និង ច្បាប់នានាដែលបានត្រូវអនុម័តរួចរាល់ ដោយរដ្ឋសភា ហើយ និង ឡាយព្រះហស្តលេខាលើរាជក្រឹត្យនានា ទៅតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី" ដែរ (មាត្រា ទី ២៣, ២៧ និង ២៨) ។

## *សិទ្ធិពលរដ្ឋ និង ករណីយកិច្ច*

*សិទ្ធិមនុស្ស*

.... រដ្ឋធម្មនុញ្ញបានទទួលស្គាល់សិទ្ធិមនុស្សដែលមានចែងច្បាស់លាស់នៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកល អំពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងអស់ដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និង សិទ្ធិកុមារ (មាត្រាទី ៣១) ។

... ពលរដ្ឋកម្ពុជា ត្រូវមានសិទ្ធិស្មើៗគ្នាចំពោះមុខច្បាប់ (មាត្រា ៣១) ។

*ករណីយកិច្ច*

... បុគ្គលម្នាក់ៗ (គ្រប់ៗរូប) មិនអាចប្រើសិទ្ធិរបស់ខ្លួនតាមវិធីណាមួយដែលប៉ះពាល់ដល់សិទ្ធិ និង សេរីភាពរបស់អ្នកដទៃឡើយ (មាត្រាទី ៣១) ។

... ពលរដ្ឋកម្ពុជាគ្រប់ៗរូប ត្រូវតែគោរពច្បាប់រដ្ឋធម្មនុញ្ញ ហើយនិងប្រតិបត្តិតាមច្បាប់ ។ ពលរដ្ឋម្នាក់ៗ មានកាតព្វកិច្ចផ្តល់វិភាគទានដល់ការកសាង និង ការការពារជាតិ (មាត្រាទី ៤៩) ។

... ពលរដ្ឋកម្ពុជាទាំងអស់ ត្រូវតែគោរពគោលការណ៍របស់អធិបតេយ្យភាពជាតិ និង លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ហើយក៏ត្រូវគោរពទ្រព្យសម្បត្តិសាធារណៈ និង ទ្រព្យសម្បត្តិឯកជនស្របច្បាប់ផងដែរ (មាត្រាទី ៥០) ។

*សិទ្ធិនយោបាយ*

... ពលរដ្ឋកម្ពុជាមិនអាចត្រូវអោយគេដកហូតសញ្ជាតិ ឬ ក៏ត្រូវគេនិរទេសខ្លួនឡើយ (មាត្រាទី ៣៣) ។

... ទោសប្រហារជីវិតត្រូវហាមឃាត់ (មាត្រាទី ៣២) ។

... បុរស ស្ត្រី កម្ពុជា មានសិទ្ធិបោះឆ្នោត និង អាចឈរឈ្មោះអោយគេបោះឆ្នោត (មាត្រាទី ៣៤) ។

... ពលរដ្ឋកម្ពុជាទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងសកម្មភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង សកម្មភាពវប្បធម៌របស់ប្រទេសជាតិ (មាត្រាទី ៣៥) ។

*សិទ្ធិនៅកន្លែងធ្វើការងារ*

... ពលរដ្ឋគ្រប់រូបមានសិទ្ធិជ្រើសរើសមុខរបរ សមស្របតាមសមត្ថភាពរបស់ខ្លួន និង តាមសេចក្តីត្រូវការរបស់សង្គមជាតិ (មាត្រាទី ៣៦) ។

... មនុស្សទាំងពីរភេទមានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នា ចំពោះការងារដូចគ្នា (មាត្រាទី៣៦) ។

... ពលរដ្ឋទាំងអស់មានសិទ្ធិបង្កើតសហជីពពាណិជ្ជកម្ម មានសិទ្ធិធ្វើកូដកម្ម និង ធ្វើបាតុកម្មដោយសន្តិភាពបំផុត (មាត្រាទី ៣៧) ។

*ដំណើរការរៀបចំកាត់ក្តីដ៏សមស្របតាមច្បាប់*

... ច្បាប់រដ្ឋធម្មនុញ្ញហាមប្រាមមិនអោយមានការវាយតប់គ្នាទៅលើរាងកាយអ្នកដទៃឡើយ តែច្បាប់ជួយការពារជីវិត កិត្តិយស និង សេចក្តីថ្លៃថ្នូររបស់មនុស្ស (មាត្រាទី ៣៨) ។

... ការចាប់ខ្លួន ការឃុំឃាំង និង ការដាក់មនុស្សអោយជាប់ពន្ធនាគារអាចអនុវត្តធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ (មាត្រាទី ៣៨) ។

ការបង្ខិតបង្ខំ ការធ្វើបាប លើរូបរាង្គកាយ ឬ ព្រឹត្តកម្មណាមួយ មិនត្រូវបានយកមកធ្វើជាភស្តុតាងជាប់ពិរុទ្ធទេ ( មាត្រា ៣៨ ) ។

ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។ ជនគ្រប់រូបមានសិទ្ធការពារខ្លួន តាមផ្លូវតុលាការ ( មាត្រា ៣៨ ) ។

ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬ ប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពី អំពើខុសច្បាប់ របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការ ( មាត្រា ៣៩ ) ។

## ភាពដាច់ពីគេ ឬឯកភាពសំងាត់ និងសេរីភាពពីការឆែកឆេរដោយខុសច្បាប់

ការរក្សាសិទ្ធិមិនអោយរំលោភលើលំនៅដ្ឋាន និងអាថ៌កំបាំង នៃការឆ្លើយឆ្លង តាមលិខិត និងតាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និងតាមទូរសព្ទត្រូវបានធានា ( មាត្រា ៤០ ) ។

ការផ្លាស់ប្តូរលំនៅដ្ឋាន សម្ភារៈវត្ថុ និងឈើរូបបុគ្គល ត្រូវធ្វើអោយស្របនឹង បញ្ញត្តិច្បាប់ (មាត្រា ៤០) ។

## សេរីភាពការធ្វើដំណើរ

ប្រជាពលរដ្ឋខ្មែរ អាចចេញទៅតាំងលំនៅ នៅប្រទេសក្រៅ ឬ ត្រលប់ មកវិញបាន (មាត្រា ៤០ )។

សេរីភាពការបញ្ចេញយោបល់ និង សាសនា មតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជន ណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធនេះដោយរំលោភ នាំអោយប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទំលាប់ របស់សង្គម ដល់សណ្តាប់ធ្នាប់សារធារណៈ និងដល់ សន្តិសុខជាតិ បានឡើយ (មាត្រា ៤១ ) ។

ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិបង្កើត សមាគម និង គណៈបក្សនយោបាយ ( មាត្រា ៤២ )

សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងលក្ខណ្ឌ ដែលមិនប៉ះពាល់ដល់ជំនឿ ឬ សាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ។ ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ (មាត្រា ៤៣ ) ។

*រដ្ឋសភា*

... រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០ រូប ដែលត្រូវបោះឆ្នោះជ្រើសតាំង "ដោយសេរី ដោយស្មើភាព និងដោយផ្ទាល់តាមវិធីជ្រើសរើសឆ្នោតជាសំងាត់" (មាត្រា ៧៦) ។

... នីតិកាលរបស់រដ្ឋសភាមានកំណត់ ៥ ឆ្នាំ ។ "បើស្ថិតក្នុងពេលមានសង្គ្រាម ឬក៏ក្នុងកាលៈទេសៈពិសេសណាមួយ ដែលមិនអាចធ្វើការបោះឆ្នោតបាននោះ រដ្ឋសភាអាចប្រកាសពីការពន្យា ឬ បន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ ទៅតាមសំណើ ឬ យោបល់របស់ព្រះមហាក្សត្រ ។ ការពន្យាពេល ឬ ការបន្តនីតិកាលនេះ ត្រូវសំរេចដោយមតិយល់ព្រម ២/៣ យ៉ាងតិចនៃសមាជិករដ្ឋសភា" ទាំងមូល (មាត្រា ៧៨) ។

... សមាជិករដ្ឋសភាគ្រប់ៗរូប ត្រូវមានអភ័យឯកសិទ្ធិសភា ។ គេអាចធ្វើការចាប់ខ្លួនសមាជិករដ្ឋសភាបានឃុំឃាំងខ្លួនបាន ឬ ក៏ដាក់ពន្ធនាគារបាន លុះត្រាណាតែមានការឯកភាពព្រមព្រៀងពីរដ្ឋសភា ឬ ពីគណៈកម្មាធិការអចិន្ត្រៃយ៍សិន បើរដ្ឋសភាត្រូវបញ្ឈប់ លើកលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង (មាត្រា ៨០) ។

... រដ្ឋសភាប្រជុំសាមញ្ញ ២ ដងក្នុងមួយឆ្នាំ ដែលការប្រជុំនីមួយៗមានរយៈពេលយ៉ាងតិច ៣ ខែ (មាត្រា ៨៣) ។

*រាជរដ្ឋាភិបាលកម្ពុជា*

... គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលរបស់កម្ពុជា ដែលមាននាយករដ្ឋមន្ត្រី ដែលជួយជាជំនួយដោយឧបនាយករដ្ឋមន្ត្រី (អាចមានច្រើនរូប) និងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និង រដ្ឋលេខាធិការ ជាសមាជិក (មាត្រា ៩៩) ។

... សមាជិករបស់រាជរដ្ឋាភិបាល ស្ថិតនៅក្រោមការទទួលខុសត្រូវរួមរបស់រដ្ឋសភា លើគោលនយោបាយទូទៅ (រួម) របស់រាជរដ្ឋាភិបាល (មាត្រា ១០២) ។

*អំណាចតុលាការ*

... តុលាការត្រូវមានឯករាជ្យពីសាខាទាំងអស់ របស់រដ្ឋាភិបាល ។ "អំណាចតុលាការធានាអនាគតិ និង ការពារសិទ្ធិ សេរីភាពរបស់ពលរដ្ឋ" (មាត្រា ១០៩) ។

... ព្រះមហាក្សត្រ ដែលមានជំនួយប្រោមប្រែងពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមផងនោះ ព្រះអង្គជាអ្នកធានាអោយមានឯករាជ្យភាពរបស់តុលាការ (មាត្រា ១១៣) ។

... ចៅក្រមមិនអាចត្រូវគេដកមុខងារបានឡើយ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចសំរេចដាក់វិន័យលើចៅក្រមដែលបានប្រព្រឹត្តខុស (មាត្រា ១១៤) ។

... ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រ អំពីការតែងតាំងចៅក្រម និង ព្រះរាជអាជ្ញាអមសាលាជំរះក្តីទាំងអស់ (មាត្រា ១១៥) ។

... ការរៀបចំសាខាតុលាការរបស់រដ្ឋាភិបាល ត្រូវកំណត់ក្នុងច្បាប់ដោយឡែកពីគ្នា (មាត្រា ១១៦)។

*ក្រុមប្រឹក្សាធម្មនុញ្ញ*

... ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចធានា ការពារការគោរពរដ្ឋធម្មនុញ្ញ ហើយនិងបកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់នានាដែលអនុម័តដោយរដ្ឋសភា ។ ក្រុមប្រឹក្សានេះ មានសិទ្ធិពិនិត្យ និងសំរេចអំពីករណីវិវាទកម្មទាក់ទិនទៅនឹងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ។

... ក្រុមប្រឹក្សានេះ មានសមាជិកប្រាំបួនរូប ហើយ ១/៣ នៃសមាជិកទាំងនេះ ត្រូវផ្លាស់ប្តូរវេងរាល់បីឆ្នាំម្តង ។ សមាជិក ៣ រូប ត្រូវតែងតាំងដោយព្រះមហាក្សត្រ ៣ រូបទៀត ត្រូវជ្រើសតាំងដោយរដ្ឋសភា និង ៣ រូបទៀត ត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (មាត្រា ១១៨) ។

... ព្រះមហាក្សត្រនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា ឬក៏ ១/១០ នៃតំណាងរាស្ត្រ អាចបញ្ជូនសេចក្តីព្រាងច្បាប់នានា ទៅអោយក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុនពេលដែលច្បាប់នោះត្រូវបានប្រកាសអោយប្រើប្រាស់ (មាត្រា ១២១) ។

... រាល់បទបញ្ញាផ្ទៃក្នុងរដ្ឋសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅអោយក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុនពេលប្រកាសអោយប្រើ (មាត្រា ១២១) ។

... បន្ទាប់ពីច្បាប់មួយ ត្រូវបានប្រកាសអោយប្រើប្រាស់ហើយ ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា ១/១០ នៃរាស្ត្រ ឬ តុលាការ អាចសុំអោយក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ (មាត្រា ១២២) ។

... ពលរដ្ឋគ្រប់រូបមានសិទ្ធិប្តឹងអំពីធម្មនុញ្ញភាពនៃច្បាប់តាមរយៈតំណាងរបស់ខ្លួន នៅក្នុងរដ្ឋសភា ឬក៏តាមរយៈប្រធានរដ្ឋសភា ដូចមានចែងក្នុងវាក្យខណ្ឌខាងលើ (មាត្រា ១២២) ។

## IV. ច្បាប់អន្តរជាតិ

ពលរដ្ឋកម្ពុជាក៏មានសិទ្ធិពាក់ព័ន្ធនឹងការបោះឆ្នោត និង ការចូលរួមក្នុងដំណើរការងារនយោបាយដែរ ក្រោមច្បាប់អន្តរជាតិ ។ រដ្ឋធម្មនុញ្ញរបស់កម្ពុជាបានទទួលសិទ្ធិទាំងនេះជាពិសេស ហើយមាត្រា ៣១ នៃច្បាប់រដ្ឋធម្មនុញ្ញបានចែងថា ៖

ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និង គោរពសិទ្ធិមនុស្សដូចមានចែងក្នុង ធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលអំពីសិទ្ធិមនុស្ស និង កតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងអស់ ដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ ។

សេចក្តីប្រកាសជាសកលនៃសិទ្ធិមនុស្ស បានចែងនៅក្នុងមាត្រា ២១ ថា ៖

១. ជនណាក៏ដោយ មានសិទ្ធិចូលរួមជាមួយរដ្ឋាភិបាលនៃប្រទេសរបស់គេ ដោយផ្ទាល់ ឬ តាមរយៈអ្នកតំណាងរបស់ខ្លួនដែលបានត្រូវជ្រើសរើសដោយសេរី ។

២. ជនណាក៏ដោយ មានសិទ្ធិដើម្បីកាន់តំណែងបំរើការងារសាធារណៈ នៅប្រទេសរបស់ខ្លួន ក្នុងលក្ខខណ្ឌនៃសមភាព ។

៣. ឆន្ទៈរបស់ប្រជាពលរដ្ឋ គឺជាមូលដ្ឋានគ្រឹះនៃអាជ្ញាធររបស់រដ្ឋអំណាច ហើយឆន្ទៈនេះនឹងត្រូវសំដែងចេញនៅពេលមានការបោះឆ្នោតទាំងឡាយដ៏ទៀងត្រង់ ដែលត្រូវប្រារព្ធឡើង ហើយមានលក្ខណៈជាសកលស្មើភាព សំងាត់ ឬ ដោយនីតិក្រមទាំងឡាយណាដែលមានតំលៃស្មើគ្នានេះហើយដែលជួយធានាអោយមានការបោះឆ្នោតដោយសេរី ។

កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយបានពន្យល់នៅក្នុងមាត្រា ២៥ ថា ៖

ពលរដ្ឋម្នាក់ៗ មានសិទ្ធិ និង មានលទ្ធភាពក្នុងការ ៖

១. ចូលរួមក្នុងកិច្ចការនានានៃការងារសាធារណៈដោយផ្ទាល់ ឬ តាមរយៈអ្នកតំណាងខ្លួនដែលត្រូវបានជ្រើសតាំងដោយសេរី ។

២. បោះឆ្នោត និង ឈរឈ្មោះជាបេក្ខជនអោយគេបោះឆ្នោត ទៅតាមកាលៈទេសៈដែលបានកំណត់ទុកដ៏ត្រឹមត្រូវ ។ ពិធីបោះឆ្នោតនេះ ត្រូវមានលក្ខណៈជាសកល សិទ្ធិស្មើគ្នាក្នុងការបោះ

ឆ្នោត គឺឆ្នោតដែលបោះត្រូវលាក់ការជាដាច់ខាត ដើម្បីធានាអោយមានការសំរេចមតិដោយសេរីអំពីសំណាក់អ្នកបោះឆ្នោត ។

៣. មានសិទ្ធិស្មើៗគ្នាជាទូទៅ ក្នុងការបំរើសាធារណៈជនក្នុងប្រទេសរបស់ខ្លួន ។

## V. ការអប់រំអ្នកបោះឆ្នោត (សូមមើលជំពូកទី ៣ (Module 3) នៃសៀវភៅសំរាប់បណ្តុះបណ្តាល)

បើគិតទៅដល់ថ្ងៃបោះឆ្នោតខាងមុខនេះ ឃើញថា វាមានរយៈពេលជា ៤ ឆ្នាំមកហើយ រាប់តាំងពីការបោះឆ្នោតមុនមួយនោះ ។ វាជារឿងមួយធម្មតាទេ ដែលប្រជាពលរដ្ឋនៅប្រទេសភាគច្រើនតែតែងផាកលែងនិយាយគ្នាអំពីរឿងនយោបាយ ក្នុងចន្លោះពេលពីពេលបោះឆ្នោតមួយទៅពេលបោះឆ្នោតមួយទៀតនោះ ។ ចំពោះប្រជាពលរដ្ឋខ្មែរភាគច្រើនដែលយើងនឹងជជែកជាមួយ ឬ ដែលយើងនឹងបង្រៀនគាត់នោះគិតទៅវាមានរយៈពេលច្រើនឆ្នាំណាស់មកហើយ តាំងតែពីពេលដែលពួកគាត់ធ្លាប់បានជជែកគ្នាអំពីបញ្ហានានាពាក់ពន្ធ័ទៅនឹងការបោះឆ្នោតនោះ ។ ដូច្នេះគោលបំណងរបស់កម្មវិធីធ្វើការអប់រំអ្នកបោះឆ្នោតនេះ គឺចង់ជួយជំរាបដល់ពលរដ្ឋកម្ពុជា អោយបានយល់ដឹងអំពីការកែប្រែខ្លះៗក្នុងប្រពន្ធ័បោះឆ្នោតនាថ្ងៃខាងមុខ ដោយយើងនឹងបង្រៀនគាត់អោយពួកគាត់បានយល់ដឹងអំពីបេក្ខជន និង បញ្ហានានាដែលពាក់ពន្ធ័ ព្រមទាំងជួយពួកគាត់អោយយល់កាន់តែច្បាស់ថា អ្នកបោះឆ្នោតត្រូវមានភាពប្រាជកនិយមក្នុងចិត្តលើការបោះឆ្នោត និង ជួយជំរុញលើកទឹកចិត្តពួកគាត់អោយពួកគាត់ទៅចូលរួមបោះឆ្នោះ ។ ច្បាប់បោះឆ្នោតថ្នាក់ឃុំ និង ថ្នាក់រដ្ឋសភា នៅមិនទាន់បានអនុម័តនៅឡើយទេ តែនៅដែលច្បាប់ទាំងនោះបានត្រូវអនុម័តហើយ ច្បាប់នោះនឹងមានពត៌មានសំខាន់ៗអំពីថា តើគេនឹងធ្វើការបោះឆ្នោតនៅពេលណា ហើយនិងថាតើមានទំរង់ការជាក់លាក់អ្វីខ្លះ ដែលគេយកមកប្រើប្រាស់សំរាប់បោះឆ្នោតនោះ ។ យើងនៅមិនទាន់ដឹងនៅឡើយថា ប្រពន្ធ័បោះឆ្នោតនឹងមានលក្ខណៈបែបណាទេ ឧទាហរណ៍ថា : តើជាការបោះឆ្នោតមួយបែបនិយមភាគច្រើនបំផុត ឬ ក៏បែបជាប្រពន្ធ័មួយផ្អែកលើចំនួនសមាមាត្រ ឬ ក៏ជាអ្វីពិតប្រាកដនោះឡើយ ប៉ុន្តែឯកសារបន្ថែម និងសៀវភៅសំរាប់បណ្តុះបណ្តាលនេះ នឹងមានការកែប្រែបន្ថែមបន្ថយទៀត កាលណាច្បាប់ថ្មីៗទាំងនេះត្រូវបានអនុម័តរួច ។ តែទោះជាយ៉ាងនេះក្តី ក៏នៅមានពត៌មានសំខាន់ៗជាច្រើនទៀតដែរ ដែលយើងអាចជូនទៅពលរដ្ឋអោយបានដឹងយល់ជ្រួតជ្រាបមុនពេលដែលច្បាប់ទាំងនោះត្រូវអនុមត័នោះ ដូចជា ត្រូវដឹងអំពីសារៈសំខាន់នៃការចូលរួមក្នុងការងារនយោបាយជាដើម ។ល។

តទៅនេះ គឺជាសារៈតាខ្លះៗ ស្តីអំពីការបោះឆ្នោតដែលយើងត្រូវចងចាំជានិច្ច នៅពេលយើងបង្រៀនផ្នែកទី ៣ នៃសៀវភៅបណ្តុះបណ្តាលនេះ ។

### *<u>ក. ប្រពន្ធ័បោះឆ្នោត</u>*

ប្រពន្ធ័បោះឆ្នោតវាមានការងារជាច្រើន ដូចជាការតែងតាំងគណៈកម្មការបោះឆ្នោត ការចុះឈ្មោះអ្នកបោះឆ្នោត និង ការគ្រប់គ្រង (ផ្នែករដ្ឋបាល) ការបោះឆ្នោតនៅថ្ងៃបោះឆ្នោត (ឧទាហរណ៍ ដូចជាថា : តើត្រូវប្រើសន្លឹកឆ្នោតប្រភេទណា តើអាចឬមិនអាចអោយមានអ្នកសង្កេតការណ៍អន្តរជាតិ ឬ ក្នុងស្រុកមានវត្តមាននៅស្ថានីយ៍បោះឆ្នោតឬក៏អត់ ហើយនិងថាតើត្រូវរាប់សន្លឹកឆ្នោតរបៀបណា) ជាដើម ។ល។ រឿង

ដែលសំខាន់មួយក្នុងបណ្តាបញ្ហាសំខាន់ៗជាច្រើននោះគឺ ការជ្រើសរើសយកប្រព័ន្ធមួយដែលអាចយកទៅប្រើប្រាស់ដើម្បីកំណត់ថាអ្នកណាដែលជាអ្នកបោះឆ្នោត ឧទាហរណ៍ : តើបេក្ខជនត្រូវឈ្នះឆ្នោតនៅពេលដែលគេបានទទួលសន្លឹកឆ្នោតភាគច្រើន លើសពី ៥០%) ឬក៏ថាអាចមានអ្នកឈ្នះលើសពីម្នាក់នៅតាមមណ្ឌលបោះឆ្នោតនីមួយៗ តាមស្រុកនីមួយៗដែលបោះឆ្នោតដោយសារថា កៅអីនឹងត្រូវបានទៅតាមចំនួនសមាមាត្រានោះ ឬក៏យ៉ាងណា ? តទៅនេះ គឺជាសេចក្តីសង្ខេបរៀបរាប់អំពីវិធី ៣ យ៉ាង ដែលប្រព័ន្ធបោះឆ្នោះ ត្រូវតែរៀបចំឡើង ៖

- *<u>ប្រព័ន្ធពហុភាព</u>*

  បើជាប្រព័ន្ធពហុភាព មានមនុស្សតែម្នាក់ ឬក៏មានតែគណបក្សមួយប៉ុណ្ណោះ ដែលត្រូវបោះឆ្នោតជ្រើសរើសនៅតាមស្រុក (មណ្ឌលបោះឆ្នោតនីមួយៗ ។ ប្រព័ន្ធនេះជួនកាលគេអោយឈ្មោះហៅថាប្រព័ន្ធ "អ្នកឈ្នះយកទាំងអស់" ឬក៏ជាប្រព័ន្ធ "អ្នកទីមួយបានតំណែង" ពីព្រោះមានអ្នកឈ្នះតែមួយប៉ុណ្ណោះ នោះមានន័យថា គឺជាបេក្ខជនដែលទទួលបានសន្លឹកឆ្នោត ច្រើនជាងបេក្ខជនឯទៀតៗ ។ ជាឧទាហរណ៍ បើមានបេក្ខជន ៣ នាក់ ឈរឈ្មោះអោយគេបោះឆ្នោត ហើយមានមនុស្ស (បេក្ខជន) ម្នាក់ទទួលបានចំនួនសំលេងឆ្នោតច្រើនជាងគេបងស់បានឈ្នះ ទោះជាមានអ្នកបោះឆ្នោតភាគច្រើនមានការពេញចិត្តបេក្ខជន ២ នាក់ទៀតនោះក៏ដោយ ។ ប្រព័ន្ធនេះ គេមានប្រើប្រាស់នៅក្នុងសហរដ្ឋអាមេរិក និងនៅតាមបណ្តាប្រទេសជាច្រើនទៀត ដែលនិយាយកាសាអង់គ្លេស ។

- *<u>ប្រព័ន្ធយកចំនួនភាគច្រើន</u> / <u>ប្រព័ន្ធឯកត្តនាម</u>*

  ដូចជាប្រព័ន្ធពហុភាពអញ្ចឹងដែរ គឺមានមនុស្សតែម្នាក់ប៉ុណ្ណោះ ដែលត្រូវបោះឆ្នោតជ្រើសរើសនៅតាមស្រុក (មណ្ឌល) បោះឆ្នោះនីមួយៗ ។ តែអ្វីដែលវាខុសគ្នាពីប្រព័ន្ធពហុភាពនោះ គឺអ្នកឈ្នះត្រូវទទួលចំនួនភាគច្រើនបំផុត (យ៉ាងតិចត្រូវ ៥០% + ១) នៃសន្លឹកឆ្នោតដែលគេបានបោះ ។ ប្រការនេះអាចតំរូវអោយមានការបោះឆ្នោតពីរដង ។ ឧទាហរណ៍ : បើមិនមានបេក្ខជនណាម្នាក់ទទួលបានចំនួនភាគច្រើននៃសំលេងឆ្នោតទាំងអស់ទេនោះ គេត្រូវធ្វើការបោះឆ្នោតជាលើកទី ២ ដែលពេលនោះបេក្ខជនដែលបានទទួលសំលេងឆ្នោតច្រើនបំផុត ត្រូវប្រកួតប្រជែងជាមួយគ្នា (ឧទាហរណ៍មាន : បេក្ខជន ២ រូប ដែលបានសំលេងឆ្នោតលើសគេបំផុត កាលពីបោះលើកទី ១) នោះ ។ នេះគឺជាប្រព័ន្ធមួយដែលគេប្រើ នៅប្រទេសបារាំង ហើយប្រព័ន្ធនេះត្រូវបានគេកែប្រែផ្សេងៗពីគ្នា យកទៅប្រើប្រាស់នៅតាមបណ្តាប្រទេសអឺរ៉ុបខាងកើត ជាច្រើនប្រទេស ។

- *<u>ប្រព័ន្ធសមាមាត្រ</u>*

  ការបោះឆ្នោតកាលពីឆ្នាំ ១៩៩៣ នៅកម្ពុជា បានត្រូវគេឆ្លើយឡើង តាមប្រព័ន្ធសមាមាត្រដែលមានន័យថា មានបេក្ខជនលើកទី ១ រូប ដែលត្រូវជ្រើសរើសនៅតាមស្រុក (មណ្ឌល) បោះឆ្នោតនីមួយៗ ។ ចំនួនកៅអីដែលគណបក្សនីមួយៗឈ្នះ គឺត្រូវផែកលើភាគរយនៃសំលេងឆ្នោតសរុបដែល

គណបក្សនោះទទួលបាន ឧទាហរណ៍ ដូចជាមណ្ឌលដ៏ធំមួយនៅប្រទេសនេះ គឺនៅខេត្តកំពង់ចាម មានតំណាងរាស្ត្រ ១៨ រូប បានត្រូវប្រជារាស្ត្របោះឆ្នោតជ្រើសរើស នៅពេលបោះឆ្នោត ថ្នាក់ជាតិខាងមុខនេះ បើគណបក្សមួយបានទទួល ២/៣ នៃសំលេងឆ្នោតទាំងអស់នោះ គណបក្សនោះត្រូវបានទទួល ១២ កៅអី តែបើមានគណបក្សណាមួយបានទទួល ១/៣ នៃសំលេងឆ្នោតវិញនោះ គណបក្សនោះ នឹងបានទទួល ៦ កៅអី ។

ប្រព័ន្ធទាំងបីដូចបានរៀបរាប់ខាងលើនេះ មានការកែប្រែច្រើនណាស់ ដូចជានៅប្រទេសអាល្លឺម៉ង់ (ឧទាហរណ៍) មានប្រព័ន្ធចំរុះមួយដែលមានសមាជិកអង្គនីតិបញ្ញត្តិមួយចំនួនដែលគេហៅថា (Bundestag) នោះត្រូវបោះឆ្នោតជ្រើសរើសតាមប្រព័ន្ធសមាមាត្រ ហើយខ្លះៗទៀត ត្រូវបោះឆ្នោជ្រើសរើសតាមប្រព័ន្ធពហុភាព ។ គេគ្មានប្រព័ន្ធ "ត្រូវ" ទេ គឺប្រព័ន្ធនីមួយៗអាចមានប្រយោជន៍ នឹងមិនមានប្រយោជន៍ ។

## ខ. *ការចុះឈ្មោះអ្នកបោះឆ្នោត*

ការចុះឈ្មោះនេះ គឺជាការងារមួយសំរាប់កំណត់ (សំគាល់រក) អ្នកមានសិទ្ធិបោះឆ្នោត និងសំរាប់ការពារមិនអោយអ្នកមិនមានសិទ្ធិចូលទៅបោះឆ្នោតបាន ។ ការងារនេះ ក៏ទប់ស្កាត់ប្រជារាស្ត្រមិនអោយបោះឆ្នោតបានលើពីម្តង ឬក៏ទៅបោះឆ្នោតខុសកន្លែងដែរ ។ សិទ្ធិ (លក្ខណៈសម្បត្តិ) របស់អ្នកបោះឆ្នោត គឺត្រូវកំណត់ដោយរដ្ឋធម្មនុញ្ញរបស់ជាតិ និងដោយច្បាប់បោះឆ្នោត ។ មាត្រាទី ៣៤ នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជា (ឧទាហរណ៍) បានចែងថា :

"ពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងឈរឈ្មោះអោយគេបោះឆ្នោតជ្រើសរើសខ្លួន" ។

"ពលរដ្ឋកម្ពុជាទាំងពីរភេទ មានអាយុយ៉ាងតិច ១៨ ឆ្នាំ ឡើងទៅ នោះត្រូវមានសិទ្ធិបោះឆ្នោត"។

លក្ខណៈសម្បត្តិ "សិទ្ធិ" សំរាប់បោះឆ្នោតនោះ ក៏មានឥទ្ធិពលមកលើដោយច្បាប់សញ្ជាតិផងដែរ ដែលបានលើកឡើងនៅក្នុងសៀវភៅបណ្តុះបណ្តាលនេះស្រាប់ ។ ច្បាប់បោះឆ្នោតដែលត្រូវកំណត់លក្ខណៈសម្បត្តិ ឬ សិទ្ធិសំរាប់បោះឆ្នោតនោះ នៅពុំទាន់បានត្រូវអនុម័តនៅឡើយទេ ។ ច្បាប់នោះ (ឧទាហរណ៍) អាចលើសពីតំរូវការកំណត់អំពីភាពជាពលរដ្ឋពេញសិទ្ធិរបស់កម្ពុជា ។ ច្បាប់នេះ ក៏មានលើកអំពីបញ្ហានានាដូចជា តើប្រជាជនកម្ពុជាដែលរស់នៅបរទេស អាចបោះឆ្នោតបានយ៉ាងណានោះដែរ ។

★ *តើអ្វីទៅជាការ "បោះឆ្នោតសេរី និង មានយុត្តិធម៌" ?*

អង្គការនានាដូចជា សហជីពអន្តរសភានោះ បានរកឃើញខ្នាតគំរូសំរាប់ការបោះឆ្នោតសេរី និងមានយុត្តិធម៌ ។ មានសំណួរចាំបាច់ៗមួយចំនួន ដែលត្រូវលើកយកមកសួរ ដើម្បីអោយដឹងថា តើការបោះឆ្នោតមួយ មានលក្ខណៈសេរី និង មានយុត្តិធម៌ ឬក៏អត់នោះ មាន ៖

- តើច្បាប់បោះឆ្នោតទាំងអស់មានយុត្តិធម៌ដល់គណបក្ស និង បេក្ខជនទាំងអស់ឬទេ ?
- តើមនុស្សពេញវ័យទាំងអស់ បានត្រូវអនុញ្ញាតអោយចុះឈ្មោះ (បោះឆ្នោត) ឬទេ ?

- តើគ្រប់គណបក្សនយោបាយទាំងអស់ ត្រូវបានគេអនុញ្ញាតអោយធ្វើយុទ្ធនាការបោះឆ្នោតរកថវិកា និងធ្វើការប្រជុំនានា ដោយសេរី មិនមានការបង្ខិតបង្ខំជំទាស់ ឬ គ្មានអំពើហឹង្សាឬទេ ?
- តើគ្រប់គណបក្សទាំងអស់ មានលទ្ធភាពប្រើប្រាស់ប្រពន្ធ័ផ្សព្វផ្សាយពត៌មានដែលរដ្ឋកាន់កាប់ ឬ គ្រប់គ្រងនោះឬទេ ?
- តើមានធនធានរដ្ឋណាមួយត្រូវរដ្ឋយកទៅប្រើប្រាស់ខុសឆ្គង ដើម្បីគាំទ្រដល់បេក្ខជនណាមួយដែលខ្លួនពេញចិត្ត ឬក៏ជាគណបក្សណាមួយដែលខ្លួនពេញចិត្តនោះឬទេ ?
- តើអ្នកបោះឆ្នោតអាចទៅកាន់ទីបោះឆ្នោតនៅថ្ងៃបោះឆ្នោត ហើយអាចបោះឆ្នោតសំងាត់របស់គេដោយគ្មានសេចក្តីភ័យខ្លាចអំពើហឹង្សាណាមួយឬទេ ?
- តើអ្នកបោះឆ្នោត បានទទួលពត៌មានអំពីបេក្ខជនឈរឈ្មោះគ្រប់ៗរូប និង គេដឹងអំពីដំណើរការបោះឆ្នោតឬទេ ?
- តើការបោះឆ្នោតតម្លាភាពឬទេ ? តើពលរដ្ឋគ្រប់ៗរូប បានទទួលពត៌មានអំពីថា តើគេជ្រើសរើសមន្ត្រីផ្នែកបោះឆ្នោតដោយរបៀបណា ហើយតើអ្នកសង្កេតការណ៍អន្តរជាតិ និង អ្នកសង្កេតការណ៍ក្នុងស្រុក ត្រូវបានអនុញ្ញាតអោយពិនិត្យមើលគ្រប់ទិដ្ឋភាពនៃការងារបោះឆ្នោត ដូចជាការរាប់សន្លឹកឆ្នោតនោះឬទេ ?